សារព័ត៌មាន ខ្មែរប៉ុស្ដិ៍ ស.រ.អា
KhmerPost USA
FREE BIWEEKLY CAMBODIAN ENGLISH NEWSPAPER SINCE 2007
978-677-7163 • VISIT KHMERPOST.US

7 Video
ទទួលផ្ញើអីវ៉ាន់ ទៅវិញទៅមកស្រុកខ្មែរ
- ផ្ញើ១ផោន តម្លៃ ១០ដុល្លារ
- ធានា បើសិន បាត់ ឬបាក់បែក
- ដឹកជញ្ជូនដល់ផ្ទះ
ទំនាក់ទំនង ៖ Mr. យុទ្ធ (978) 876-1985
660 Middlesex St., Lowell, MA 01851
(978)710-6356

## ការបរិភោគអាហារដើម្បីសុខភាពសម្រាប់ពលរដ្ឋក្រុងឡូវែល

សូមអាននៅទំព័រទី ០៥



## អនុគណកម្មការពិនិត្យពាក្យបណ្តឹងក្រុងឡូវែលចេញ

សូមអាននៅទំព័រទី ០៤



## ពីរសប្តាហ៍សម្រាប់ជួបក្រុមគ្រួសារនៅប្រទេសបារាំង

សូមអាននៅទំព័រទី ០៦



# ពិធីសម្ពោធរូបសំណាកខ្មែរភៀសខ្លួននៅបរិវេណសាលាក្រុង

**ឡូវែល៖** ចាប់ពីពេលនេះតទៅនៅពេលខ្មែរយើងទៅដល់សាលាក្រុងឡូវែលយើងនឹងបានឃើញរូបសំណាកថ្មខ្មែរភៀសខ្លួន កំពស់ជិត២ម ជាស្នាដៃរបស់វិចិត្រករ យ៉ារី លីវ៉ាន ពេលនោះយើងនឹងភ្ញាក់ខ្លួនថា "រូបនេះហើយដែលបញ្ជាក់ថាអាត្មា អញមកពីណា?" ។

ដោយសារការប្រឹងប្រែងនឹងដឹកនាំដោយលោក រ៉តនី អេលីយ៉ុត សមាជិកក្រុមប្រឹក្សាក្រុងនឹងជាអតីតអភិបាលក្រុង,

**តទៅទំព័រទី ០៣**



រ៉ត នីអ៊ុលីយ៉ុត    យ៉ារី លីវ៉ាន់

## LOWELL VOTES បោះឆ្នោតបឋម៖ បេក្ខជនក្រុមប្រឹក្សាក្រុង ថ្ងៃទី ២៦ ខែកញ្ញា

អ្នកអាចជ្រើសរើសបេក្ខជនបានរហូតដល់ ៩ នាក់


Jeffrey ចេហ្វ្រី Wilson វិលសិន


Karen ឃារិន Cirillo ស៊ីរីលឡូ


Robert W. រ៉ូប៊ឺត Merrill, Jr. មឺរីល


Sokhary សុខារី Chau ចៅ


David J. ដេវីដ Conway ខន់វ៉េ


Corey A. ខូរី Belanger បេឡឹនជឺ


Edward J. អ៊ែដវឺដ Kennedy, Jr. ឃែណ្ណឌី


Joseph ចូសេហ្វ Boyle បយល៍


Rita M. រីតា Mercier មឺស៊ៀ


James "Jim" L. ចេមស៍ Milinazzo មីលីណាហ្សូ


Vesna វាសនា Nuon នួន


Matthew មែធ្យូ LeLacheur ឡឺឡាស្ហឺ


Daniel ដេញ៉ូល Finn ហ្វីនន៍


Paul Ratha ផល រដ្ឋា Yem យ៉ែម


Daniel P. ដេញ៉ូល Rourke រួក


William "Bill" វីល្លៀម Samaras សាម៉ារ៉ាស


Jose "Willie" ហូហ្សេ Negron ណេហ្គ្រិន


John J. ចន Leahy ឡេហ៊ី


Pan ប៉ាន So សូ


Robert រ៉ូប៊ឺត Gignac ហ្គិកណាក់


Rodney M. រ៉ដនី Elliott អ៊ីលៀត


Martin J. ម៉ាធិន Hogan ហូហ្គិន


James "Jim" ចេមស៍ Leary លៀរី

សូមកុំភ្លេចទៅបោះឆ្នោត! មណ្ឌលបោះឆ្នោតនឹងមានបុគ្គលិកធ្វើការចាប់ពីម៉ោង ៧ ព្រឹករហូតដល់ម៉ោង ៨ ល្ងាច ឬអ្នកអាចស្នើសុំសន្លឹកឆ្នោតសម្រាប់អ្នកអវត្តមាន (absentee ballot) ដើម្បីឲ្យអ្នកអាចបោះឆ្នោតនោះត្រឹមថ្ងៃត្រង់មួយថ្ងៃមុនថ្ងៃបោះឆ្នោត!

តនៅទំព័រទី១១

# បានទទួលមួយ ឬទាំងពីរក្នុងចំណោមប័ណ្ណទាំងនេះ?

# ទទួលយកបន្ថែម។




ទទួលយកអត្ថប្រយោជន៍ច្រើនជាងអ្វីដែលអ្នកបច្ចុប្បន្នកំពុងទទួលបានពី Original Medicare និង MassHealth ជាមួយគម្រោង **UnitedHealthcare® Senior Care Options (HMO SNP)**។ វារួមបញ្ចូលគ្នានូវវេជ្ជបណ្ឌិតរបស់អ្នក មន្ទីរពេទ្យ និងការគ្រប់ដណ្ដប់ឱសថមានវេជ្ជបញ្ជាគ្រប់ទៅក្នុងគម្រោងមួយ គឺសម្រាប់ បុព្វលាភរ៉ាប់រងគម្រោង **$0**។**

## អត្ថប្រយោជន៍បន្ថែមអាចរួមមាន៖

**ឱសថមានវេជ្ជបញ្ជា**
រាប់ពាន់នៃឱសថអាចប្រើបាន។

**ការគ្រប់ដណ្ដប់លើទន្តសាស្ត្រ**
សហចំណាយ **$0** សម្រាប់ការដាក់ធ្មេញ និងក្រាសធ្មេញពាក់។

**ជំនួយលើមធ្យោបាយធ្វើដំណើរ**
សហចំណាយ **$0**សម្រាប់ការជិះទៅជួបវេជ្ជបណ្ឌិតតាមការណាត់។

**កាតាឡុកផលិតផលសុខភាព**
រហូតដល់ទៅ **$320** ក្នុងឥណទានប្រចាំឆ្នាំដើម្បីទិញ ផលិតផលសុខភាពពីកាតាឡុករបស់យើង។

**ទូរស័ព្ទមកថ្ងៃនេះដើម្បីចុះឈ្មោះ ឬទទួលបានចម្លើយទៅនឹងសំណួររបស់អ្នក។**



BOPHA PEOU
License # 2016784

**Contact # (978) 221-9970, TTY 711**
[8 a.m. – 8 p.m. local time, 7 days a week]

**UHCCommunityPlan.com/MA**

UnitedHealthcare
Community Plan

UnitedHealthcare SCO គឺជាគម្រោងថែទាំសុខភាពដែលមានការសម្របសម្រួលមួយ ដែលមានកិច្ចសន្យាជាមួយ Medicare និងជាប់កិច្ចសន្យាជាមួយកម្មវិធី Commonwealth of Massachusetts Medicaid ។ ការចុះឈ្មោះនៅក្នុងគម្រោងគឺផ្អែកទៅលើការបន្តកិច្ចសន្យាជាថ្មីរបស់គម្រោងជាមួយ Medicare ។ គម្រោងនេះគឺជាកម្មវិធីស្ម័គ្រចិត្ត ដែលអាចរកបានសម្រាប់អ្នកដែលមានវ័យចាប់ពី 65 ឆ្នាំឡើងទៅ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ MassHealth Standard និង Original Medicare ។ ប្រសិនបើលោកអ្នកមាន MassHealth Standard ប៉ុន្តែលោកអ្នកមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីទទួលបាន Original Medicare លោកអ្នកនៅតែមានសិទ្ធិចុះឈ្មោះក្នុងគម្រោង MassHealth Senior Care Option និងទទួលបានអត្ថប្រយោជន៍ MassHealth ទាំងអស់របស់លោកអ្នកតាមរយៈកម្មវិធី SCO របស់យើង។ ព័ត៌មាននេះគឺមិនមែនជាការពិពណ៌នាពេញលេញអំពីអត្ថប្រយោជន៍នោះទេ។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកគម្រោង។ ការកំណត់សហចំណាយ និងការដាក់កំហិតនានាអាចត្រូវអនុវត្ត។ អត្ថប្រយោជន៍ បុព្វលាភរ៉ាប់រង និង/ឬសហចំណាយ/សហធានារ៉ាប់រងអាចផ្លាស់ប្ដូរនៅថ្ងៃទី 1 ខែមករានៃឆ្នាំនីមួយៗ។ បុព្វលាភរ៉ាប់រង សហចំណាយ សហធានារ៉ាប់រង និង ថ្លៃបង់ប្រចាំឆ្នាំមុនពេលធានារ៉ាប់រងបង់ឲ្យ អាចប្រែប្រួលតាមកម្រិតនៃជំនួយបន្ថែមដែលលោកអ្នកទទួលបាន។ សូមទាក់ទងមកគម្រោងសម្រាប់ព័ត៌មានលំអិតបន្ថែមទៀត។ អ្នកចុះឈ្មោះមិនតម្រូវឲ្យបង់ប្រាក់ពីហោប៉ៅឡើយ។

H2226_150915_093829 Accepted
UHCSCO_150915_093829
CST10056_ H2226-001

តមកទំព័រទី ០១

# ពិធីសម្ពោធរូបសំណាកខ្មែរភៀសខ្លួន...



រូបសំណាក "តំណាងឱ្យសហគមន៍ខ្មែរ" ស្មើដោយប្រជាពលរដ្ឋភាគតិចជាអតីតជនភៀសខ្លួនខ្មែរ បានត្រូវសម្ពោធ នាថ្ងៃអាទិត្យទី២៤ កញ្ញា២០១៧ នេះ វេលាម៉ោង១២ដោយមានប្រជាពលរដ្ឋប្រមាណ៤០០នាក់ចូល ជាមួយនឹងមន្ត្រីសាលាក្រុងនឹងមិត្រភក្ត្រនៃសហគមន៍ខ្មែរចូលរួម ព្រមទាំងអភិបាលក្រុង អេដ កេណ្ណែឌី អមដោយសមាជិកក្រុមប្រឹក្សាក៏បានចូលរួមយ៉ាងកុះករដែរ។ ក្រុមល្ខោនបាសាក់ ក្រុមភ្លេងខ្មែរ ក្រុមឆៃយ៉ាំ បានបញ្ចេញស្នាដៃសិល្បៈរួមដោយក្រុមរបាំប្រពៃណី ក៏បានមករួមអបអរពិធីសម្ពោធរូបសំណាកនៅមុខសាលក្រុងឡូវែល ។



កាត់ខ្សែបូសម្ពោធរូបសំណាកខ្មែរ





លោក វ៉តនី បានបើកសម័យសម្ពោធដោយនិមន្តព្រះសង្ឃគ្រប់វត្តនៅឡូវែលមកចំរើនព្រះបរិត បន្ទាប់មកមានធ្វើពិធីគោរពទង់ជាតិអាមេរិកាំង នឹងខ្មែរ ដោយមានសិល្បករចម្រៀង សាមី ស៊ីន ច្រៀងភ្លេងជាតិជូនផង។ មុននឹងដល់ពីធីកាត់ខ្សែបូរ លោក វ៉តនីបានសម្តែងការអរគុណដល់ភ្ញៀវអ្នកដែលមកចូលរួមកកកុញអរគុណដល់សិល្បករ យ៉ារី ឡីវ៉ាន ដល់ក្រុមអ្នកជំនួយការ៤រូប មាន វណ្ណា ហូវ៉ាត - សុខផល ប៉ែន - មូលិកា ទៀង ជាពិសេសគ្រួសារនាង ស៊ូសី ដែលប្តីទើបនឹងចែកឋានទៅក៏បានទទួលនូវការស្ងើងស្ញាធគោរពវិញ្ញាណក្ខន្ធ១នាទី។ លោក វ៉តនី បានសម្តែងការអរគុណជាបន្តដល់អ្នកដែលបានឧបត្ថម្ភធំៗជាប្រាក់មានធានាគារ "ឡូហ្វាយ" មានពេទ្យធំ "ឡូវែល", មានអ្នកស្រី ហូវ៉ាត, លោក រដ្ឋា យ៉ែម នឹងមានអ្នកស្រី សូបិន ពិន នៃកាសែតខ្មែរផុស ស.រ.អា. ផងដែរ...។

មុននឹងបញ្ចប់ លោក អេដ កេណ្ណឺឌី អភិបាលក្រុងឡូវែល បានថ្លែងសុន្ទរកថាខ្លីមួយថា: "រូបសំណាក់នេះដំណាងឱ្យការចងចាំពីមនុស្ស២លាននាក់បានស្លាប់កាលពីជំនាន់ឆ្នាំ១៩៧៥ នឹងចងចាំពីមនុស្សដែលបានមកដល់ទីនេះរួមរស់ជាមួយយើង, ហើយដែលសំខាន់នោះលោក យ៉ារី លីវ៉ាន ជាសិល្បករម្នាក់ក្នុងចំណោម៣នាក់ដែលសល់ពីស្លាប់ ហើយតែម្នាក់ឯងគត់ដែលបានមកដល់ឡូវែលនេះហើយទទួលបានការកោតសសើរ, ហើយស្នាដៃនៅទីលានសាលាក្រុងនេះ មានន័យថា ជាការចូលរួមរស់របស់សហគមន៍ខ្មែរ ជាមួយជនជាតិឯទៀតៗដូចជាអាយរីស-បារាំង-ក្រិក-នឹងសាសន៏ឯទៀតជាច្រើន...៕


# ដំណោះស្រាយការឱ្យខ្ចី សម្រាប់លំនៅដ្ឋាន

កំពុងចង់ទិញផ្ទះថ្មីមួយនៅក្នុងរដ្ឋម៉ាស្សាជូស្សេត្ស៍, ញ៉ូហេមសឺរ ឬម៉េន ឬស្វែងយល់ពីអត្ថប្រយោជន៍នៃការបង់ប្រាក់ជាថ្មី? ពួកយើងជាអ្នកមានការដពិសោធន៍ ខាងនិក្ខេបនឹងជួយណែនាំ លោក-អ្នកឆ្លងកាត់ពីដំណាក់កាលដំបូងនៃការ ជ្រើសរើសហិរញ្ញវត្ថុ រហូតដល់ដំណាក់កាលចុងក្រោយនៃការទិញ។ ជាមួយនឹង ការសម្រេចដែលត្រូវធ្វើឡើង ជាមូលដ្ឋានយើងមានភាពបត់បែន និងឆ្លើយតប ហើយនិងអាចបង្កើត ដំណោះស្រាយ អោយបានលឿន និងមានប្រសិទ្ធិភាព។

មជ្ឈមណ្ឌលនិក្ខេបនៅ
នៅធនាគាររអេនធ័រប្រាយស៍
978-656-5653 | 877-671-2265



យើងផ្តល់នូវកម្មវិធី និងសេវាកម្មជាច្រើនដើម្បីជួយលោក-អ្នក ជាមួយតម្រូវការហិរញ្ញវត្ថុជាក់លាក់របស់អ្នក។

អនុវត្តនៅអនឡាញថ្ងៃនេះ!

Enterprise Bank
CREATE SUCCESS
EnterpriseBanking.com/Mortgage

Member FDIC

# អនុគណកម្មការពិនិត្យពាក្យបណ្តឹងក្រុងឡូវែលចេញសួរយោបល់ពលរដ្ឋ

**ខ្មែរផុសស.រ.អា**

ថ្ងៃទី២០ កញ្ញា២០១៧ នៅមជ្ឈមណ្ឌលមនុស្សចាស់ឡូវែលមានបើកកិច្ចប្រជុំមួយរៀបចំដោយ"ស៊ីប៊ីអេ"ស្តីអំពីអនុគណកម្មការក្រុងឡូវែលឆ្លើយតបនឹងបណ្តឹងរបស់ក្រុមជនភាគតិចក្នុង"ការគ្មានភាពជាតំណាងរបស់ខ្លួនក្នុងរដ្ឋាភិបាល"។ ពលរដ្ឋប្រមាណ៣០-៤០នាក់ បានមកជួបជុំគ្នាដើម្បីស្តាប់សេចក្តីរាយការណ៍នឹងការប្តូរយោបល់, ក្រុងឡូវែលដំណាងដោយលោក ជីម ឡេរិ- ប៊ីល សាមារ៉ាស នឹង ជន លិហ៊ី អមដោយដំណាងចាងហ្វាងក្រុងនឹងអ្នកច្បាប់២រូប ។

លោក ជីម ឡេរី បានផ្តើមសេចក្តីថា "ក្រុងឡូវែលបើកកម្មវិធីមកស្តាប់យោបល់ប្រជាពលរដ្ឋពីចំណងប្តូររបបគ្រប់គ្រងក្រុងរបស់ខ្លួន គឺជាការផ្លាស់ប្តូរដ៏សំខាន់បំផុតមួយ ដែលតម្រូវឱ្យប្រជាពលរដ្ឋទាំងអស់បានសម្តែងមតិមុននឹងក្រុមប្រឹក្សាក្រុងធ្វើសេចក្តីសម្រេចឱ្យបានស្របនឹងបំណងរបស់ពលរដ្ឋខ្លួនយើងចង់ឮពីប្រជាពលរដ្ឋថា តើគេចង់ផ្លាស់ប្តូរដែរឬទេ? បើគេចង់ផ្លាស់ប្តូរឱ្យទៅជាមានដំណាងតាមតំបន់ វានឹងមានរូបភាពគ្រប់គ្រងជាច្រើនដែលគេអាចយកជម្រាបជូនបាននៅពេលនេះ, គេអាចប្តូរពីតំណាងក្រុងពី៩នាក់ ទៅ ១១ ឬ ១៣នាក់ ទៅតាមតែសេចក្តីត្រូវការ ដូចជា៦រូប ដាក់ឱ្យបោះឆ្នោតជាទូលាយ គឺក្នុងក្រុងទាំងមូល រីឯ៥រូបទៀតឱ្យបោះឆ្នោតយកតំណាងតាមសង្កាត់ដែលខ្លួននៅ"។



លោកស្រី រីដា មីសៀ សមាជិកក្រុមប្រឹក្សាក្រុងដ៏ចាស់វស្សាបានថ្លែងថា"ខ្ញុំចង់បានឱ្យពលរដ្ឋបញ្ចេញមតិស្តីពីការគ្រប់គ្រងនេះ តាមការបោះឆ្នោត នោះហើយជាអំណាចរបស់ពលរដ្ឋ ខ្ញុំយកថារបៀបគ្រប់គ្រងសព្វថ្ងៃជាការសមរម្យហើយ ខ្ញុំជាដំណាងរបស់ទាំងអស់គ្នាមិនថាអ្នកនៅតំបន់ណាទេ អាចរកខ្ញុំបានគ្រប់ពេលតែខ្ញុំនិយាយនេះក្នុងមតិខ្លួនឯងទេ ខ្ញុំក៏អាចនឹងយល់ច្រឡំដែរ... បើមតិភាគច្រើនយល់ថា គួរតែឱ្យមានការបោះឆ្នោតដំណាងសង្កាត់ ខ្ញុំក៏យល់ស្របតាមដែរ"។

លោក កូរី បាឡិនជ័រ សមាជិកក្រុមប្រឹក្សាម្នាក់ទៀត និយាយថា "លោកបានស្តាប់យោបល់ពលរដ្ឋជាច្រើន អំពីតំណាងប្រជាពលរដ្ឋតាមសង្កាត់ គឺជាការផ្តល់ឱ្យមានការផ្លាស់ប្តូរក្នុងក្រុងដ៏សំខាន់មួយតែខ្ញុំយល់ស្របតាម លោកស្រី រីដា មីសៀ ដែលថារបៀបគ្រប់គ្រងសព្វថ្ងៃក៏ប្រសើរដែរហើយ"។

វាគ្មិនជាច្រើនជាតំណាងឱ្យតំបន់ចង់ឃើញនឹងចង់យល់ពីការដែលសង្គមឡូវែល គួរតែមានការផ្លាស់ប្តូរដូចតំបន់ឯទៀតៗដែលនៅជុំវិញ ខ្លះសួរថា"ហេតុអ្វីក៏ចាំបាច់មានដំណាងដល់ទៅពី១១-១៣រូប?" ចម្លើយគឺជា "លទ្ធផលនៃការជំរឿនប្រជាជនឆ្នាំ២០១០ ដែលប្រជាពលរដ្ឋបានកើនចំនួនច្រើនជាងមុន"

លោក ផល រដ្ឋា យ៉ែម ជាបេក្ខជនសមាជិកក្រុងប្រឹក្សាក្រុងឆ្នាំនេះ បានលើកឡើងថា "ខ្ញុំមានការលំបាកច្រើនដើម្បីឈរឈ្មោះជាតំណាងគេ ដែលមកនៅទីនេះ៣០ឆ្នាំហើយ គ្មាននរណាស្គាល់ ហើយនៅតែជាបេក្ខជននៃសហគមន៏ថ្មីជាដ៏រាប... ខ្ញុំចង់ឃើញខ្មែរមានដំណាងនឹងគេនៅក្នុងរដ្ឋាភិបាលពីព្រោះតែមានប្រជាពលរដ្ឋខ្មែរច្រើនរស់នៅទីនេះ លើកនេះខ្ញុំបានឈរឈ្មោះម្តងទៀត សង្ឃឹមថា មានគេស្គាល់ខ្ញុំច្រើនជាងមុនហើយបោះឆ្នោតឱ្យខ្ញុំដើម្បីឱ្យបានតំណាងក្រុមភាគតិចបានជាប់ឆ្នោត...

លោក សែម មាស វាគ្មិនខ្មែរម្នាក់ដែលធ្លាប់ជាបេក្ខជនព្រឹទ្ធសមាជិកនិយាយថា "ចង់ឃើញលោកអភិបាលក្រុងមានតួនាទីរឹងមាំជាអ្នកគ្រប់គ្រងក្រុងធ្វើការពេញពេលយ៉ាងហោចណាស់ក៏មានពេលធ្វើការពេញម៉ោងទទួលខុសត្រូវចំពោះមុខម្ចាស់ឆ្នោតកុំឱ្យដូចសព្វថ្ងៃទុកឱ្យតែអ្នក

**តទៅទំព័រទី ០៥**


សហគមន៏ - ការប្តេជ្ញាចិត្ត-សេវាកម្ម

សូមបោះឆ្នោតអោយ

JOHN J. LEAHY

សំរាប់ក្រុមប្រឹក្សាក្រុង

ថ្ងៃអង្គារ៍ ទី២៦ ខែកញ្ញា ឆ្នាំ២០១៧

មានលេខរៀង#11នៃបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត
លោកជាមនុស្សដែលសកម្មក្នុងសហគមន៍,ចេះយកចិត្តទុកដាក់
ចំពោះពលរដ្ឋនឹងមានចំនេះដឹងដើម្បីដោះស្រាយបញ្ហាបានត្រឹមត្រូវ។
លោកដឹកនាំសហគ្រាសឯកជនទៅកាន់រដ្ឋាភិបាល។

ឧបត្ថម្ភគណកម្មការសម្រាប់បោះឆ្នោត
អោយលោក John J. Leahy



# ការបរិភោគអាហារដើម្បីសុខភាព សម្រាប់ពលរដ្ឋក្រុងឡូវែល

ដោយ សុបិន ពិន | sobenpin@khmerpost.us

ការបរិភោគអាហារដើម្បីសុខភាពល្អ បានក្លាយជាការព្រួយបារម្ភណ៍មួយក្នុងចំណោមបញ្ហាជាច្រើនចំពោះប្រជាពលរដ្ឋរស់នៅក្នុងក្រុង។ ដោយសារតែខ្សែរចង្វាក់ផ្គត់ផ្គង់ចំណីអាហារកំពុងតែជុំរុញកាន់តែច្រើនឡើងក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ឱ្យមានការបិទផ្លាកសញ្ញាមិនមានប្រើជាតិគីមី រីសវិវាង្គលើផលិតផលកសិកម្ម គម្រោងកម្មវិធីការចាប់ផ្ដើមថ្មីក្នុងការធ្វើកសិកម្មប្រកបដោយនរនិរន្តរភាព (New Entry Sustainable Farming Program) បានចាប់ផ្ដើមនៅក្នុងកំឡុងឆ្នាំ១៩៩៨ ក្នុងក្រុងឡូវែល ដោយសាលា Fried មាននៃសកលវិទ្យាល័យ Tufts។ គោលបំណងនៃគម្រោងកម្មវិធីនេះ គឺដើម្បីជួយជនចំណាកស្រុកនិងជនភៀសខ្លួនដែលទើបមកដល់ថ្មីឱ្យមាការបរិភោគអាហារដើម្បីសុខភាពល្អ ចំណេះដឹងផ្នែកកសិកម្មសម្រាប់សម្របខ្លួនទៅនឹងការចាប់ផ្ដើមជីវិតថ្មី នៅក្នុងវិស័យកសិកម្មរបស់រដ្ឋម៉ាសាជូសេត។ កសិករនឹងទទួលបានការបណ្ដុះបណ្ដាល និងទទួលបានដីដោយចាប់ដៃគូរជាមួយនឹងអង្គការក្នុងស្រុក, ជាតិ និងអន្តរជាតិ។

គ្រួសារជនភៀសខ្លួនខ្មែរជាច្រើន បានចុះឈ្មោះចូលរួមក្នុងកម្មវិធីនេះ។ អ្នកស្រី ផល្លា



នុល រស់នៅភាគខាងជើងក្រុងអែនដវ័រ ដែលបានបន្តមុខរបរកសិកម្មបន្ទាប់ពីឪពុកចុងរបស់អ្នកស្រី បានមានប្រសាសន៏ថា អ្នកស្រីបានរៀនបង្កើតអារម្មណ៏ឱ្យចូលចិត្តការដាំដុះ តាមរយៈ

តទៅទំព័រទី ០៨

# Healthy Eating for Lowell

by Soben Pin | sobenpin@khmerpost.us

Healthy eating has become one of the main concerns in urban families. As the food chains are trying to promote more organic labels in their supermarkets in recent years, New Entry Sustainable Farming Program has been launched in 1998 in Lowell by Tufts University's Friedman School of Nutrition Science and Policy. The purpose of this program was to help recent immigrants and refugees with farming backgrounds to integrate their new lives into Massachusetts agriculture. Farmers would receive training and get land access through partnership with local, state, and national organizations.

Many Cambodian refugee families have signed up for this program. Phalla Noel of North Andover, who took over farming business after her late father, says she learned to like farming by working with her father in the last decade. It has helped to secure her family members job even it remains seasonal.

She received training about land use, how to grow vegetables and where to market her produce.

Phalla grows at least 60 different kind of vegetables many of which are preferred food for Cambodian/ Asian. Not only people like Phalla are able to grow Cambodian culturally appropriate food, but many other members of Lowell diverse community are also participate in this program. You can meet them at Lowell's Farmer market every Friday from July through October at Lucy Larcom Park, 258 Merrimack Street 12 - 5pm.

Urban families can have access to affordable locally grown organic fruits and vegetables for nearly 4 months. These vendors accept major credit cards, WIC, SNAP/EBT, and senior coupons. The Lowell Farmer's Market is sponsored by the Community Teamwork and authorized by the Continued to Page 07




តមកទំព័រទី ០៤ អនុគណកម្មាធិការពិនិត្យពាក្យបណ្ដឹង...

គ្រប់គ្រងក្រុងធ្វើការឱ្យនោះ។

ការប្រជុំដើម្បីឱ្យគណកម្មការក្រុងឡូវែលទទួលបន្ទុក"ករណីបណ្ដឹងពីជនភាគតិច"ក្នុងក្រុង គឺស្វែងរកការពន្យល់ផ្នែកច្បាប់នឹងទទួលយកយោបល់ពីម្ចាស់ឆ្នោតតាមសង្កាត់ពីវិធីដែលសមាជិកក្រុមប្រឹក្សាក្រុងគួរអនុម័តសម្រេចចិត្តយកគំនិតរបស់អ្នកប្ដឹង ឬក៏បន្តការតទល់គ្នានៅតុលាការ គឺនឹងមានធ្វើការពន្យល់របៀបនេះច្រើនដងនៅឱ្យមតិនៃតំបន់ឯទៀតៗយល់ថា "ខ្មែរមិនចាប់អារម្មណ៏ចំពោះគុណភាពសង្គមដែលខ្លួនឯងរស់នៅទេ", ថម នៃវិទ្យុក្នុងឡូវែលមួយ មានយោបល់ថា "ប្រសិនបើមានការជ្រើសយក" ឱ្យមានតំណាងសង្កាត់និមួយៗគេនឹងឃើញតំណាង ខ្លះមានអ្នកគាំទ្រ៥-៦ពាន់នាក់ រីឯសង្កាត់ខ្លះ ទៀតនឹងក្លាយជាតំណាងតែពលរដ្ឋ១ពាន់នាក់ តែប៉ុណ្ណោះ (យោងតាមការមិនចេញទៅបោះ






ច្រើនកន្លែងផ្សេងទៀត ហើយអាចនឹងបង្ករឱ្យមានការធ្វើប្រជាមតិលើបញ្ហាប្តូរភាពជាតំណាងប្រជាពលរដ្ឋឱ្យមាន "ដំណាងតាមសង្កាត់ ឬក៏រក្សាភាពជាតំណាងនៅដដែល?"។

សហគមន៏ខ្មែរមិនមានចេញមកបង្ហាញមតិខ្លួនទេនេះជាហេតុធ្វើ



ឆ្នោត) ដូច្នេះនៅតែមានសង្កាត់ធំដែលមានឥទ្ធិពលលើសង្កាត់តូចដដែល។ មតិនេះមិនខុសទេ ប្រសិនបើយើងគិតរាយមាយថា "ការបោះឆ្នោតជាការឥតប្រយោជន៏ទេ" នោះ៕

# ពីរសប្ដាហ៍សម្រាប់ជួបក្រុមគ្រួសារនៅប្រទេសបារាំង

**ដោយ ពិន សំខុន**

ទៅប្រទេសបារាំងលើកនេះ គឺយើងមានបំណងទៅទស្សនានៅតំបន់ខាងជើងឈៀងខាងលិចនៃប្រទេសបារាំង គឺ"ឡាប្រឺតាញ - ឡា Bretagne"ម្ដងទៀត បន្ទាប់ពីបានទៅកាលពី៣-៤ឆ្នាំមុន ដោយសារចង់ធ្វើដំណើរតាម "រថភ្លើងដ៏លឿនបំផុតក្នុងលោក-TGV"ឱ្យបានយ៉ាងហោចណាស់ក៏បានម្ដងដែរមុននឹងត្រឡប់មកអាមេរិកវិញ, តែមិនបានធ្វើទៅវិញ ដោយឃើញតម្លៃធ្វើដំណើរវាខ្ពស់ពេល (ជាង៤០០អឺរ៉ូ ប្រមាណ៥០០ដុល្លា) ហើយម្យ៉ាងទៀតពេលវេលាបានខូចខាតច្រើនអស់៣-៤ថ្ងៃ នៅពេលចេញដំណើរពីបូស្តុនទៅហើយ យើងក៏ប្ដូរដំណើរនោះទៅ "ន័រម៉ងឌី- Normandie" ដែលនៅពាក់កណ្ដាលផ្លូវជាផ្នែកតំបន់ទេសចរភាគខាងជើងឈៀងខាងលិចវិញម្ដង គឺតាមរថយន្តដែលយើងជួល២០០ដុល្លាក្នុងរយៈពេល៩ថ្ងៃ។ តែមុននឹងចេញដំណើរនៅថ្ងៃស្អែកឡើង យើងឆ្លៀតឱកាសនៅរសៀលជួលឡានបាននោះ ទៅទស្សនាវិហារប្រវត្តិសាស្ត្របារាំង"ណូត្រឺដាមដឺប៉ារីស- Notre Dame de Paris" នឹងសង្កាត់ដែលនៅក្បែរគ្នា គឺសង្កាត់"កាជេឡាតាំង - Quartier Latin" ជាមុនសិន ។

**២-វិហ៊ារណូត្រឺដាម និង កាជេឡាតាំង :** នៅលើផ្លូវទៅកណ្ដាលក្រុងប៉ារីសតាមមាត់"ទន្លេសែន" យើងបានឈប់នៅ "ទូអឺហ្វែល" ដើម្បីថតរូបនៅកន្លែងដែលគ្រួសារលោក ផលរដ្ឋា យ៉ែម



នៅជាមួយគ្រួសារ



នៅវង្គសាល

ទៅពីឡូវែលយើងដែរ នោះទើបនឹងបង្ហោះតាម "ហ្វេសប៊ុក" កាលពីខែមុន, រួចយើងបន្តតែបន្តិចក៏ទៅដល់ "កោះឡាស៊ីតេ- Ile de la Cite" ដែលនៅកណ្ដាលទន្លេសែនទីនោះវិហ៊ារកាតូលិកជំនាន់សតវត្សទី១១ គឺ "ណូត្រឺដាមដឺប៉ារីស" បានលេចធ្លោ ពោរពេញដោយមនុស្សម្នាមកទស្សនាកកកុញមកទស្សនាវិហ៊ារនោះមិនដាច់។ គឺនៅកន្លែងនោះឯង ដែលជាចំណុចគីឡូម៉ែត្រ "សូន្យ" ដែលចេញពីនេះទៅ គេផ្ដើមរាប់ចម្ងាយឆ្ងាយ ឬជិតពីទីកណ្ដាលរដ្ឋធានីក្រុងប៉ារីសទៅកាន់តំបន់ផ្សេងៗទៀត។ យើងបាននាំ ប៊ុណ្ណារ៉ូ ចូលទៅទស្សនារហូតដល់ភាគខាងក្នុងនៃព្រះវិហ៊ារ ពីព្រោះជាឈ្មោះ"ណូត្រឺដាម"ជាឈ្មោះសាលាដែល ប៊ុណ្ណារ៉ូ កំពុងរៀនសព្វថ្ងៃ នៅឡូវែលនាសហរដ្ឋអាមេរិកនេះដែរ។ សំណង់ចាស់ឆ្នាំនៃជំនឿរបស់ជនជាតិបារាំង"ណូត្រឺដាម"បានផ្ដើម តាំងពីសតវត្សទី១១ (ស្មើគ្នានឹងជំនាន់សង់អង្គរវត្តដែរ) ហើយប្ដូររូបរាងនៅកន្លែងដដែល រហូតមកដល់សតវត្សទី១៩ ទើបកំណត់យករូបរាងជាចុងក្រោយដូចសព្វថ្ងៃនេះ។ នៅខាងក្នុងភាពអស្ចារ្យនៃជំនឿមនុស្សនៅរក្សាយ៉ាងពេញទំហឹង គឺពុំមែនជាប្រវត្តិនៃអតីតកាលទេ តែជាបច្ចុប្បន្នភាពនៃមនុស្សកំពុងតែជឿ...មនុស្សរាប់រយពាន់នាក់ដើរបន្តកន្ទុយគ្នាយ៉ាងស្ងប់ស្ងៀមក្រេបជញ្ជក់ប្រវត្តិដ៏ត្រកាលនឹងជំនឿប្រចាំត្រកូលយ៉ាងយកចិត្តទុកដាក់នឹងសណ្ដាប់ធ្នាប់ជាទម្លាប់ ។

វិហ៊ារ"ណូត្រឺដាម"នៅប៉ារីសជាវិហ៊ារដ៏ល្បីល្បាញបំផុតនៅអឺរ៉ុប ដោយសារតែប្រវត្តិដ៏យូរលង់នឹងឥទ្ធិពលនៃសាសនាកាតូលិកនៅក្នុងតំបន់ដែលគ្របដណ្ដប់លើនយោបាយនៃប្រទេសទាំង

តទៅទំព័រទី០៧

# កម្ពុជាផ្ដើមបង្ហាត់សត្វកណ្ដុរសម្រាប់បោសសម្អាត់មីន

**ដោយខ្មែរផុស ស.រ.អ**

បច្ចុប្បន្ននេះបើទោះបើជាប្រទេសកម្ពុជាមានការអភិវឌ្ឍន៏គួរឱ្យកត់សម្គាល់លើផ្នែកហេដ្ឋារចនាសម្ព័ន្ធ និងសេដ្ឋកិច្ចក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះយ៉ាងណាក៏ដោយ តែកម្ពុជានៅតែជាប្រទសមួយទទួលរងផលប៉ះពាល់ដោយសារគ្រាប់មីននិងគ្រាប់មិនទាន់ផ្ទុះច្រើនជាងគេនៅលើពិភពលោកដោយសារសង្គ្រាមពីអតីតកាល។

គ្រាប់មីន និងគ្រាប់មិនទាន់ផ្ទុះទាំងនោះបានធ្វើឱ្យមនុស្សស្លាប់, ពិការ, បំផ្លាញទ្រព្យសម្បត្តិ និងការភ័យខ្លាចដល់កុមារ និងកសិករជាច្រើនក្នុងការធ្វើស្រែចំការ។ មិនត្រឹមតែកុមារ និងកសិករទេដែលទទួលរងគ្រោះ កាលពីដើមឆ្នាំនេះមានមន្ត្រីបោសសម្អាតគ្រាប់មីនស៊ីម៉ាក់ ក៏បានស្លាប់ និងរងរបួសធ្ងន់ធ្ងរដោយសារគ្រាប់មីន។

ដើម្បីកាត់បន្ថយការគ្រោះថ្នាក់ដល់មនុស្សពីការផ្ទុះមីន និងបង្កើនការបោសសម្អាតមីនឱ្យកាន់តែលឿនមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា (CMAC) បានចាប់ផ្ដើមអនុវត្តគម្រោងហ្វឹកហ្វឺនសត្វកណ្ដុររាវរកមីនកាលពីឆ្នាំ ២០១៥



ដើម្បីហ្វិតហាត់សត្វកណ្ដុរក្នុងការហិតរកមីន? ក្នុងប្រទេសកម្ពុជា។

បើយោងការរបាយការណ៏របស់អង្គការ Apopoដែលជាអង្គការក្រៅរដ្ឋាភិបាលរបស់ប្រទេសបែលហ្ស៊ិកបានឱ្យដឹងថា សត្វកណ្ដុរត្រូវបាននាំយកមកពីទ្វីបអាហ្វ្រិក ហើយត្រូវបានបង្ហាត់ឱ្យហិតរកមីន ដោយសារវាតូច និងមានទំងន់ស្រាលមិនអាចធ្វើឱ្យមីនផ្ទុះបានទេ។ ហើយវាធ្វើការបានរហ័សជាងមនុស្ស។ គេធ្វើការបង្ហឹកវាចាប់ពីអាយុមួយខែ ដោយឱ្យហាត់ហិតរកតែប្រភេទមីនដែលមានរំសេវ TNT តែប៉ុណ្ណោះ។

កណ្ដុរអាចរាវរកមីនលើផ្ទៃដីប្រមាណ ១០០ ម៉ែត្រការ៉េ ចំណាយរយៈពេលតិចជាង ២០នាទី ដោយមិនមានចន្លោះមីនណាមួយនោះទេ ចំណែកមនុស្សវិញ ត្រូវចំណាយពេលរហូតដល់ទៅ២ថ្ងៃឯណោះ។ នៅពេលកណ្ដុរធ្វើសកម្មភាពហិតប៉ះក្លិនមីន វានឹងផ្ដល់សញ្ញាដោយយកជើងរបស់វាកាយដីលើកន្លែងដែលមានមីន។

ប្រទេសកម្ពុជានៅមានគ្រាប់មីន និងគ្រាប់មិនទាន់ផ្ទុះប្រហែល៤ លាន់គ្រាប់ស្ថិតនៅមានផ្ទៃដីជិត២ពាន់គីឡូម៉ែតក្រឡា ដូច្នេះសត្វកណ្ដុរមានតួនាទីសំខាន់សម្រាប់ជួយបោសសម្អាត់មីននៅកម្ពុជានាពេលខាងមុខ៕

តមកទំព័រទី ០៦

# ពីរសប្តាហ៍សម្រាប់ជួបក្រុមគ្រួសារ...

ឡាយក្នុងតំបន់នឹងគ្របដណ្តប់លើទំនៀមទម្លាប់នៃសង្គមមនុស្សទៀតផង ហើយអ្នកគ្រប់គ្រងនៃជំនឿនេះ ក៏មានមហិច្ឆតាពង្រីកឥទ្ធិពលនៃសាសនានេះ ទៅលើពិភពលោកទាំងមូលទៀតផង។ នៅក្នុងវិហារដ៏ធំទូលាយនោះ សិល្បៈថៃរក្សារូបភាព រូបចម្លាក់ នឹងសម្ភារៈប្រើប្រាប់បានត្រូវថៃរទាំយ៉ាងប្រុងប្រយ័ត្ន ដូចជាសារមន្ទីមួយដែរ ដើម្បីការចងចាំដ៏ត្រឹមត្រូវរបស់សាធារណជនបារាំង។

"សង្កាត់កាកជេឡាតាំង"នៅចំពីមុខវិហារ "ណូត្រឺដាម" ឆ្លងទន្លេ "សែន" តាមស្ពានចាស់មួយ "កាកជេឡាតាំង"ជាឈ្មោះសង្កាត់ដ៏ល្បីមួយនៃទីក្រុងប៉ារីស ដែលទេសចរ គេមិនសូវចោលមិនទៅទស្សនានោះទេ។ គេទៅមើលទេសភាពប្រជាប្រីយនៃមនុស្សចម្រុះសាសន៍ ដែលមកកកកុញតាមផ្លូវដែលមិនមានរថយន្តបើកបរទេសចរច្រើនតែជាយុវវ័យ ពីព្រោះជាតំបន់ដែលព័ទជុំដោយមហាវិទ្យាល័យធំៗនឹងល្បីល្បាញនៃទីក្រុងប៉ារីស ដូចជាមហាវិទ្យាល័យពេទ្យសាកលវិទ្យាល័យ "ស៊ របោន" មហាវិទ្យាល័យប៉ារីស៦ នឹងប៉ារីស៧ ជាដើម។ គេទៅទីនោះដើម្បីភ្លក់ម្ហូបភ្លក្សម្ហូបឈ្ងុយឆ្ងាញ់នៃជនជាតិ ក្រិក ឥណ្ឌា ស្បាទីស ចិន ជប៉ុន... ណើងសញ្ជាតិច្រើនទៀត, ដែលជាហាងតូចៗនៅជាប់គ្នាប្រជែងសម្ផស្សនឹងក្លិនម្ហូប, គេក៏ទៅទិញរបស់អនុស្សាវរីយចម្លែកៗ, ឬទិញសៀវភៅចាសចម្រៀងចាស់ឆ្នាំដែលនៅសែសសល់ ឬក៏ទៅស្តាប់ចម្រៀងដែលនៅមានប្រជាប្រីយភាពរបស់មនុស្សជំនាន់ចាស់...ទាំងនោះជារូបភាពនៃទីផ្សារជំនាន់មុនដែលនាំអារម្មណ៍ទេសចរឱ្យត្រឡប់ចូលទៅកាន់ពិភពនៃអតីតកាលមួយរយៈបាន។



នៅវិហារនតត្រឺដាមដឺបារីស





ទៅទិញក្រសង់សម្រាប់អាហារពេលព្រឹក

និស្សិត, សិល្បករ, ពាណិជ្ជករដឹករទេះ, តែងតែមកបញ្ចូញស្នាដៃ នៅទីធ្លាមុំនោះ នៃរថភ្លើងក្រោមដីឈ្មោះ"មេត្រូឡាស៊ីតេ"ទាក់ទាញក្រសែភ្នែកសាធារណជនធ្វើឱ្យកាជេឡាតាំងប្តូរបរិយាកាសប្តូរពណ៌នៃអារម្មណ៍ធ្វើការទទួលការចងចាំពីតំបន់នេះខុសៗគ្នាទាំងអស់នឹងធ្វើឱ្យទេសចរចង់ត្រឡប់ទៅទីនោះវិញ ស្ទើរគ្រប់គ្នា។

ស្អែកឡើងយើងមិនភ្លេចស្រស់ស្រូបពេលព្រឹករបស់យើងនៅហាងកាហ្វេតូចច្រឡឹងមួយនាចំណតរថភ្លើងជនបទដ៏ស្ងាត់ជ្រងុំមួយតែអ៊ូអរក្នុងហាងដោយអ្នកស្រុកទំនេរពីការងារមកចាក់"ការប្រណាំងសេះ"នៅទីនោះ។ ទិដ្ឋភាពជាគ្រួសារគេ"បុស្ស៊ួរ"គ្នា គេ"ឃិះ" គ្នាជជែកពីមេឃល្អនាព្រឹកនេះ ពីសេះដែលរត់ឈ្នះពីម្សិលមិញ... ចំណែកយើងបីនាក់នឹងបងប្រុសជាម្ចាស់ផ្ទះទទួលយើងនាំគ្នាទៅទិញនុំបុ័ង"ក្រួសង់"ក្តៅៗមកហូបនៅហាងកាហ្វេនៅជាប់គ្នាជាមួយអារម្មណ៍ជាអ្នកស្រុក"ឆន់តឺលូឡៃវិញ" គួរឱ្យរំភើបពេកណាស់។

ម៉ោង១១ហើយ យើងចេញដំណើរទៅ "ណ័រម៉ង់ឌី"តំបន់ទេសចរបារាំងដ៏ធំមួយ តែល្បីនៅអាមេរិកនេះដោយសារចម្បាំងលោកលើកទី២ ដែលសម្ព័ន្ធមិត្តរំដោះប្រទេសបារាំងពីដៃ "អាល្លឺម៉ង់"ប្តើមវាយឆ្មក់ពិទិនោះទៅរហូតដល់បានជោគជ័យជាស្ថាពរ...។

**(នៅមានតទៅលេខក្រោយទៀត)**




Continued from page 05

# Healthy Eating for Lowell

Department of Agriculture. "We are looking to grow our program next year. Expect to see more music, more activities for kids such as art and crafts at Lucy Larcome Park or people can just come to lunch and do some shopping" says Susan Brittain.

If you are already in farming business and interested in becoming a produce vendor at the Lowell's Farmer market next year, you will have time till June 2018 to submit application and all required supporting documents. To get them you can visit Susan Brittain's office at 45 Kirk Street, 2nd floor, Lowell, call her at 978-654-4905 or download from www.commteam.org/farmers-market.



## តមកពីទំព័រទី ០៩ ការបរិភោគអាហារដើម្បីសុខភាព...

ការធ្វើការងារជាមួយឪពុករបស់អ្នកស្រី កាលពី១០ឆ្នាំមុន ។ការងារដាំដុះនេះ បានជួយធានានូវការងាររបស់គ្រួសារអ្នកស្រី បើទោះបីជាការដាំដុះនេះធ្វើឡើងតាមរដូវការក៏ដោយ ។ អ្នកស្រីបានទទួលការបណ្តុះបណ្តាលអំពីការប្រើប្រាស់ដី, វិធីក្នុងការដាំបន្លែ, និងកន្លែងដែលត្រូវធ្វើការផ្សព្វផ្សាយផលិតផលរបស់អ្នកស្រី ។ អ្នកស្រីផល្លា ដាំបន្លែយ៉ាងហោចណាស់៦០ប្រភេទ ដែលភាពច្រើន គឺសម្រាប់ធ្វើជាអាហារចំពោះពលរដ្ឋខ្មែរ និងអាស៊ី ។ មិនត្រឹមតែកសិករដូចជាអ្នកស្រីផល្លានោះទេអាចដាំដំណាំសម្រាប់ធ្វើជាអាហារបែបខ្មែរបានមានសមាជិកផ្សេងទៀតនៅក្នុងសហគមន៍ចំរុះជាតិសាសនៅក្រុងឡូវែល ក៏អាចចូលរួមនៅក្នុងកម្មវិធីនេះ ។ លោកអ្នកអាចជួបកសិករទាំងនោះ នៅទីផ្សារផលិតផលកសិកម្មរបស់កសិករក្រុងឡូវែលនៅរៀងរាល់ថ្ងៃ សុក្រ ចាប់ពីខែ កក្កដា ដល់ខែកញ្ញា នៅទីតាំង លូស៊ី ឡាខមផាក ដែលមានអាស័យដ្ឋាននៅផ្លូវ 258 Merrimack Street ចាប់ពីម៉ោង ១២ ថ្ងៃត្រង់ រហូតដល់ម៉ោង៥ល្ងាច ។

ពលរដ្ឋរស់នៅក្នុងក្រុងអាចរកទិញនូវបន្លែ នឹងផ្លែរឈើសរីរាង្គដែលដាំក្នុងស្រុក និងមានតំលៃសមស្របក្នុងរយៈពេលជិត៤ខែ ។ អ្នកលក់ផលិតផលទាំងនោះ ត្រូវបានទទួលការជួយឧបត្ថម្ភពីក្រុមការងារសហគមន៍ (Community Teamwork) និងមានលិខិតអនុញ្ញាតពីក្រសួងកសិកម្ម ។ "យើងខ្ញុំកំពុងតែធ្វើការពង្រីកកម្មវិធីរបស់យើងឱ្យកាន់តែធំសម្រាប់ឆ្នាំក្រោយ ។ លោក ស៊ូសាន ប្រ៊ីតថេន មានប្រសាសន៍ថា យើងរំពឹងនឹងមានតន្ត្រី, សកម្មភាពច្រើនជាងមុនទៀតសម្រាប់កុមារ ដូចជា សិល្បៈ និងសប្បកម្ម នៅទីតាំងលូស៊ី ឡាខម ផាក រីក៏ពលរដ្ឋអាចគ្រាន់តែមកចូលរួមអាហារថ្ងៃត្រង់ និងដើរទិញផលិតផលកសិកម្ម ។ ប្រសិនបើលោកអ្នកមានរបរកសិកម្មហើយ តែចាប់អារម្មណ៍ចង់ក្លាយជាអ្នកលក់នៅផ្សារផលិតផលកសិកម្មរបស់កសិករក្រុងឡូវែលសម្រាប់ឆ្នាំក្រោយ លោកអ្នកនឹងមានពេលវេលារហូតដល់ខែ មិថុនា ២០១៨ ដើម្បីដាក់ពាក្យសុំ និងបំពេញរាល់ឯកសារគាំទ្រដែលចំបាច់ជាការស្រេច ។ ដើម្បីទទួលបានឯកសារចាំបាច់ទាំងនោះ លោកអ្នកអាចមកកាន់ការិយាល័យរបស់លោក ស៊ូសាន ប្រ៊ីតថេន ដែលមានអាស័យដ្ឋានផ្លូវ 45 Kirk Street ជាន់ទី២ក្រុងឡូវែល, ទូរស័ព្ទមកលេខ 978-654-4905 រឺអាចទាញយកឯកសារពី គេហទំព័រ www.commteam.org/farmers-market ។

## កែរតម្រូវលើអត្ថបទពីលេខមុន



ព្រះអង្គ ឡែម



ព្រះអង្គ ស៊ីម

កាលពីលេខមុនយើងបានសរសេរអត្ថបទដាក់ឈ្មោះច្រឡំ ដោយអចេតនា យើងបានសរសេរថា "ព្រះតេជគុណ ស៊ីម បានចាកចេញពីវត្តត្រៃរតនារាម, តាមត្រឹមត្រូវនោះគឺ ព្រះតេជគុណ មី ឡែម ទេ ដែលចាកចេញពីវត្តត្រៃរតនារាម..." សូមព្រះអង្គទាំង២ មេត្តាអភ័យទោសចំពោះកំហុសក្នុងការផ្សាយរបស់ខ្មែរផុស ដោយអនុគ្រោះ ៕



# កម្មវិធីជំនួយផ្នែកថែទាំសុខភាពតាមផ្ទះរដ្ឋ

AccuCare
Home Care Agency
Group Adults Foster Care Program

កម្មវិធី Group Adult Foster Care (GAFC) គឺជាដំណោះស្រាយល្អបំផុតសំរាប់ចាស់ៗ ខ្មែរយើងដែលមានបញ្ហារាំរ៉ៃផ្នែកសុខភាព ឬជរាហើយមិនចង់ចាកចេញពីលំនៅដ្ឋានខ្លួនឯង ឬមិនចង់បែកពីក្រុមគ្រួសារដែលបានរស់នៅជាមួយគ្នាជាយូរមកហើយ ។ យើងអាចជួយអោយជីវិតលោកអ្នកកាន់តែប្រសើរឡើង តាមរយៈការផ្តល់នូវសេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកតែម្តង ។





ដើម្បីអាចចូលរួមក្នុងកម្មវិធីនេះបានលោកអ្នកត្រូវមានលក្ខណៈដូចខាងក្រោម :

- រស់នៅផ្ទះរដ្ឋ
  អាយុ ២២ ឆ្នាំឡើងទៅ
- មាសហែលស្តង់ដា

**ផលប្រយោជន៏ទទួលបាន :**

- ការថែទាំផ្ទាល់ខ្លួនមួយទល់មួយក្នុងផ្ទះរបស់អ្នករាល់ថ្ងៃមួយថ្ងៃមួយម៉ោងលើការ រស់នៅប្រចាំថ្ងៃ
- ជំនួយលើការគ្រប់គ្រងថ្នាំសង្កូវអ្នក
- ផែនការថែរទាំសុខភាពផ្ទាល់ខ្លួនមួយ ដែលធ្វើឡើងដោយគ្រូពេទ្យ និងខេសមានីយើ
- វាយតំលៃលើសេចក្តីត្រូវការជាប្រចាំជាបន្តបន្ទាប់
- សមាជិកអាចទាក់ទងមក ២៤ម៉ោង

***To be eligibled for GAFC you must:***

- *live in subsidized or public housing*
- *age 22 years and older*
- *eligible for Masshealth Standard*

***Benefits you will get:***

- *personal care service in your home,*
- *Medication Managemant*
- *an individual care plan developed by a registered nurse and case manager*
- *ongoing monitoring of needs*
- *24-hour access to services*

## ត្រូវការជ្រើសរើសបុគ្គលិកធ្វើការ PCA/ HHA needed for Lowell, Lynn, Revere, and Boston

ជាសេវាមានគុណភាពខ្ពស់ និងទុកចិត្តបាន
បុគ្គលិកមានសណ្តានចិត្តល្អ និងធ្វើការតាមវិជ្ជាជីវៈ
អ្នកគ្រប់គ្រង និងបុគ្គលិកនិយាយភាសាខ្មែរ

**ដើម្បីចុះឈ្មោះសូមទាក់ទងមក**
To register, please contact:
Tel: (978)735-4955, Fax: (978) 735-4956
Office: 144 Merrimack St., Suite 404. Lowell, MA 01852

# ស្វែងយល់អំពីប្រវត្តិនៃបុណ្យភ្ជុំបិណ្ឌ និងអញ្ជើញទៅវត្តឱ្យបានគ្រប់ៗគ្នា!

**(ភ្នំពេញ)៖** បុណ្យភ្ជុំបិណ្ឌជាពិធីបុណ្យមួយដែលធំជាងគេនៅក្នុងចំណោមពិធីបុណ្យទាំងអស់ ចំពោះអ្នកកាន់ព្រះពុទ្ធសាសនា។ បុណ្យភ្ជុំបិណ្ឌប្រារព្ធចាប់គិតពីថ្ងៃទី០១រោច ដល់ថ្ងៃទី១៥រោច ខែភទ្របទ សម្រាប់ឆ្នាំនេះ ចាប់ពីថ្ងៃទី០៦ ដល់ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៧។

ជារៀងរាល់ឆ្នាំនៅពេលដល់ថ្ងៃខែ ដែលត្រូវប្រារព្ធពិធីបុណ្យភ្ជុំបិណ្ឌគ្រប់បងប្អូនកូនចៅសាច់ញាតិសន្តានទាំងអស់ ទោះនៅទីជិត ឬទីឆ្ងាយតែងតែធ្វើដំណើរទៅជួបជុំគ្នា ជាពិសេសឪពុកម្តាយនៅស្រុកកំណើត ដើម្បីរៀបចំម្ហូបអាហារ បាយសម្ល ចង្ហាន់យកទៅប្រគេនព្រះសង្ឃដែលគង់នៅវត្តអារាម។ ទាំងនេះ គឺជាទម្លាប់មួយដែលគេនិយមធ្វើតៗគ្នារបស់ជនជាតិខ្មែរជាយូរមកហើយ។





### ប្រវត្តិបុណ្យភ្ជុំបិណ្ឌ

បើតាមតម្រាចារតាមប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជាបានបង្ហាញថា ពិធីបុណ្យភ្ជុំបិណ្ឌ គឺកើតមានតាំងពីបុរាណកាលមកម្ល៉េះ។ ប៉ុន្តែទាស់ត្រង់ថា កាលពីសម័យមុនគេមិនហៅថា បុណ្យភ្ជុំទេ ដោយនៅក្នុងពិធីនេះគេមានបែងចែកចេញជាពីរថ្នាក់។ ថ្នាក់ដំបូង គឺគេចាប់ផ្តើមធ្វើចាប់ពីថ្ងៃ១រោច រហូតដល់ថ្ងៃ១៤រោច ជាវារកភត្ត (ភត្តធ្វើតាមថ្ងៃ) ជាបន្តបន្ទាប់។ ចំណែកមួយថ្នាក់ទៀតគេធ្វើនៅថ្ងៃ ១៥រោច ដែលគេហៅថាបុណ្យភ្ជុំ។ ពិធីបុណ្យទាំងពីរថ្នាក់នេះ បច្ចុប្បន្នត្រូវបានយើងបូកបញ្ចូលគ្នា ហើយហៅកាត់ថា ពិធីបុណ្យបិណ្ឌភ្ជុំ។

### មូលហេតុ ដែលប្រារព្ធពិធីបុណ្យភ្ជុំ

កាលពីសម័យបុរាណកាល គេធ្វើពិធីបុណ្យនេះ គឺដើម្បីរៀបចំធ្វើសង្ឃភត្ត ទំនុកបម្រុងព្រះសង្ឃ ដែលគង់ចាំវស្សាក្នុងវត្តរយៈពេល៣ខែ ចាប់តាំងពីថ្ងៃចូលវស្សារហូតដល់ថ្ងៃចេញវស្សា។ នៅក្នុងចំណោរកាលបុរាណបានចារថា ដោយនៅក្នុងរដូវវស្សាមានភ្លៀងធ្លាក់ជោកជាំ រលឹមពព្រិចធ្វើឱ្យមានការលំបាកដល់ព្រះសង្ឃក្នុងពេលធ្វើគោចរ (ដើរ) បិណ្ឌបាត។ ហេតុដូច្នេះ ទើបបណ្តាពុទ្ធបរិស័ទនាំគ្នារៀបចំពិធីនេះ ដើម្បីផ្គត់ផ្គង់ព្រះសង្ឃប្រចាំថ្ងៃរហូតដល់ថ្ងៃចេញវស្សា។ ម្យ៉ាងវិញទៀត នៅក្នុងពិធីបុណ្យនេះ គឺធ្វើឡើងដើម្បីផ្សាយឧទ្ទិសកុសលដល់ពពួក ប្រេតជនញាតិនិងញាតិទាំង៧សណ្តាន ព្រមទាំងតំណញាតិច្រើនមហាកប្បនោះផងដែរ តាមរយៈអនុភាពនៃសង្ឃគតាទក្ខិណាទាន ដែលរស់រងទុក្ខវេទនា កើតជាប្រេតមានកម្មពៀរជាប់ទោសធ្ងន់រងកម្មក្រហល់ក្រហាយអត់ឃ្លានទាំងអស់នោះ បានរួចផុតពីក្តីលំបាកសោកសៅ។

### រដូវបុណ្យភ្ជុំបិណ្ឌ

ចាប់តាំងពីសម័យបុរាណកាល រហូតមកដល់បច្ចុប្បន្ននេះ ពិធីបុណ្យភ្ជុំបិណ្ឌនេះ គេតែងតែប្រារព្ធនៅក្នុងរដូវវស្សា ព្រោះនៅក្នុងរដូវនេះពពួកប្រេតអាចមានឱកាសច្រើនក្នុងការស្វែងរកចំណីអាហារជាងរដូវផ្សេងៗទាំងអស់។ ម្យ៉ាងវិញទៀតនៅក្នុងវស្សានរដូវអាហាររបស់ពួកប្រេតដូចជាភក់ជ្រាំ ស្លេស្ម៏ កំហាក សាកសព និងកាកសំណល់អសោចសម្បូរនៅក្នុងខែភ្លៀងផ្គរពព្រិច។ នៅក្នុងរដូវបុណ្យភ្ជុំបិណ្ឌរយៈពេល១៥ថ្ងៃនេះ មានពពួកប្រេតជន **តទៅទំព័រទី ២១**






# រឿង "មុនដំបូងខ្មែរក្រហមសម្លាប់ប៉ារបស់ខ្ញុំ" របស់ អែនជីលីណា ជោលី ចាក់បញ្ចាំងជាផ្លូវការ

**ដោយ សុខា វ័ត្ថក្ខុយ**

រឿង"មុនដំបូងខ្មែរក្រហមសម្លាប់ប៉ារបស់ខ្ញុំ" ដឹកនាំការសម្តែងដោយលោកស្រី អែនជីលីណា ជោលី បានចាក់បញ្ចាំងជាផ្លូវការនៅបណ្តាញផ្សព្វផ្សាយណេតេថលិខនៅថ្ងៃទី១៥ ខែកញ្ញា នេះ ព្រមទាំងចាក់បញ្ចាំងនៅរោងភាពយន្តមួយចំនួននៅតាមរដ្ឋជាច្រើនក្នុងទឹកដីសហរដ្ឋអាមេរិក។

សាច់រឿងនេះ ត្រូវបានដកស្រង់ចេញពីសៀវភៅដែលមានឈ្មោះថា "មុនដំបូងខ្មែរក្រហមសម្លាប់ប៉ារបស់ខ្ញុំ" បោះពុម្ពផ្សាយក្នុងឆ្នាំ ២០០១ សសេរដោយអ្នកស្រី អ៊ឹង លួង ជាជនរងគ្រោះមួយក្នុងចំណោមជនរងគ្រោះរាប់លាននាក់ ដែលបានបាត់បង់សមាជិកក្រុមគ្រួសារ ហើយបានមកដល់សហរដ្ឋអាមេរិកក្នុងនាមជាជនភៀសខ្លួននៅជុំរុំក្នុងប្រទេសថៃ នៅឆ្នាំ ១៩៨០។

រឿង "មុនដំបូងខ្មែរក្រហមសម្លាប់ប៉ារបស់ខ្ញុំ" មានរយៈពេល២ម៉ោង និង១៦នាទី គឺវាឆ្លុះបញ្ចាំងពីសាច់រឿងពិតរបស់ក្មេងស្រីអាយុ៥ឆ្នាំម្នាក់ រួមជាមួយក្រុមគ្រួសារបានឆ្លងកាត់ និងតស៊ូយ៉ាងវេទនា ដើម្បីបានរស់ជួបជុំគ្រួសារនៅក្នុងរបបខ្មែរក្រហម ពីឆ្នាំ ១៩៧៥ ដល់១៩៧៩។

ក្នុងរយៈកាលដើមខែកញ្ញានេះ តារាសម្តែង និងដឹកនាំរឿង អែនជីលីណា ជោលី និងកូនចិញ្ចឹមទាំង៦នាក់បានចូលរួមក្នុងកម្មវិធីមហោស្រពភាពយន្តជាច្រើនកន្លែងដូចជាកម្មវិធីហោស្រពភាពយន្តToronto International Film Festival 2017 ដែលមានទីតាំងនៅរដ្ឋ តូរ៉ុនតូ ប្រទេសកាណាដា, New York Premiere ក្រុងញ៉ូយ៉ក និង Telluride Film Festival ដែលមានទីតាំងនៅរដ្ឋ Colorado សហរដ្ឋអាមេរិក ដើម្បីសម្ពោធ និងបង្ហាញរឿងរបស់អ្នកនាង។



ខ្សែរភាពយន្តនេះ មិនត្រឹមតែត្រូវបានជ្រើសរើសដោយគណៈកម្មាធិការមហោស្រពភាពយន្តអូស្ការកម្ពុជាហៅកាត់ជម្រើសដើម្បីធ្វើជាតំណាងឱ្យកម្ពុជាប៉ុណ្ណោះទេ ថែមទាំងបានទទួលការចាប់អារម្មណ៍ និងការគាំទ្រពីសំណាក់ផលិតករហូលីវូចជាច្រើនផងដែរ ដោយសារតែការខិតខំប្រឹងប្រែងចូលរួមផ្សព្វផ្សាយរបស់

បើតាមព័តិមានក្នុងស្រុកក្រៅផ្លូវការបានឱ្យដឹងថា រឿង "មុនដំបូងខ្មែរក្រហមសម្លាប់ប៉ារបស់ខ្ញុំ" នឹងធ្វើការចាក់បញ្ចាំងនៅរោងភាពយន្តនៃរដ្ឋមួយចំនួនដែលត្រូវបានជ្រើសរើសជាបន្តបន្ទាប់ដូចជា នៅរដ្ឋ លូសអានជរលេស បញ្ចាំងនៅរោងភាពយន្ត The Landmark, នៅក្រុងញ៉ូយ៉កបញ្ចាំងនៅរោងភាពយន្ត Lincoln Plaza Cinemas, នៅរដ្ឋ Gatlinta បញ្ចាំងនៅរោងភាពយន្ត Landmark's Midtown Art Cinema, នៅប៊ូសស្តន់បញ្ចាំងនៅរោងភាពយន្តឡាន dmark's Kendall Square Cinemas, នៅឆីកាហ្គូ ឆីកាបញ្ចាំងនៅរោងភាពយន្តឡាន dmark's Century Centre, នៅ ដាលាស បញ្ចាំងនៅរោងភាពយន្ត Landmark's Magnolia Theatre, នៅ ហ្វីឡាដេលហ្វៀ បញ្ចាំងនៅរោងភាពយន្តឡានdmark's Ritz Bourse, នៅ សាន់ ស្វាន់ស៊ីស្កូរ បញ្ចាំងនៅរោងភាពយន្ត Landmark's Embarcadero Center Cinema, នៅ វ៉ាស៊ីនតោន ឌីស៊ី បញ្ចាំងនៅរោងភាពយន្ត ឡាន dmark's E Street Cinema និងចុងក្រោយនៅស៊ីតថលបញ្ចាំងនៅរោងភាពយន្តឡាន dmark's Crest Cinema Centre។ ការគ្រោងដាក់បញ្ចាំងនៅរោងទាំងនេះមិនត្រូវបានកំណត់ពេលវេលាច្បាស់លាស់នៅឡើយនោះទេ៕






តមកពីទំព័រទី០១

## ច្បាប់ស្តីអំពីតំណាងជនភាគតិចនៅឡូវែល តើបេក្ខជនខ្មែរយល់យ៉ាងណា?

**ខ្មែរផុសស.រ.អា**

ការប្តឹងរបស់ក្រុមជនភាគតិចពីការគ្មានភាពជាតំណាងរបស់ក្រុមភាគតិចនៅតាមសង្កាត់សាលាក្រុងឡូវែលបានធ្វើឱ្យមានការពន្យាពេលក្នុងការសម្រេចឱ្យមានភាពស្របច្បាប់តាមរដ្ឋធម្មនុញ្ញអាមេរីកាំង ។

ជាមួយគ្នានេះដែរ ទំនាស់ក្នុងការសម្រេចយក "ទីតាំងវិទ្យាល័យឡូវែល"រវាង"ដោនថោន" នឹង"ខលី"បានធ្វើឱ្យអាជ្ញាធរផ្តល់ថវិកាសំណង់ "MSBA"ផ្អាកការប្រជុំបោះថវិការ៣៥០លានរបស់ខ្លួន មកក្រុងឡូវែលមួយរយៈសិនទម្រាំឡូវែលរកដំណោះស្រាយខ្លួនឯងរួចស្រេចបាច់។

តើបញ្ហាទាំង២នេះ ប៉ះពាល់ដល់ការឃោសនារបស់បេក្ខជនខ្មែរយ៉ាងណា? សូមស្តាប់បេក្ខជនខ្មែរ-អាមេរីកាំងទាំង៤រូប តើគេយល់ យ៉ាងណា?

**ប៉ាន សូះ** "មិនថា មានច្បាប់សម្រាប់តំណាងជនភាគតិចក្នុងសង្កាត់ ឬគ្មានទេ ខ្ញុំពុំមានបញ្ហានឹងការឈរឈ្មោះជាបេក្ខជនបច្ចុប្បន្នរបស់ខ្ញុំទេ, តែខ្ញុំចូលចិត្តឱ្យមានច្បាប់សម្រាប់ឱ្យមានតំណាងជនភាគតិចនៅតាមសង្កាត់នៅមួយៗដែរ ។ ចំណែកទីតាំងរបស់វិទ្យាល័យ ខ្ញុំជាគ្រូបង្រៀនច្រើនឆ្នាំ ខ្ញុំបានសម្រេចចិត្តយកទីតាំងនៅ"ខលី"។




**ផល រដ្ឋាយ៉ែមះ** ការឈរឈ្មោះរបស់ខ្ញុំនេះ មានការលំបាកមែនទែនក្នុងការធ្វើឱ្យគេបោះឆ្នោតឱ្យខ្ញុំអញ្ចឹងជាការល្អដែរ ដែលការប្តឹងសាលាក្រុងនេះ អាចនឹងតុលាការតុលាការបង្ខំក្រុងឱ្យប្តូររបៀបបោះឆ្នោតផ្តល់ឱ្យមានច្បាប់សម្រាប់ជនភាគតិចក្នុងសង្កាត់ ទោះជាខ្ញុំធ្លាក់ឆ្នោតលើកនេះ ក្តីក៏សង្ឃឹមថាលើកក្រោយនឹងមានការងាយស្រួលជា។ ចំណែកទីតាំងវិទ្យាល័យខ្ញុំចង់បានវិទ្យាល័យថ្មីត្រូវនឹងសតវត្សរបស់គេឱ្យកូនខ្ញុំរៀន គឺនៅ"ខលី"




**សុខារី ឆារះ** ជនភាគតិចយល់ថា មានភាពអយុត្តិធម៌សម្រាប់ពួកគេក្នុងការគ្មានតំណាងនៅសាលាក្រុងតែខ្ញុំមានទំនាក់ទំនងល្អជាមួយនេង ជណផែតិចទាំងអស់ដែលខ្ញុំសង្ឃឹមថានឹងអាចឈ្នះឆ្នោតបានដែរ ។




**វ៉ាសនា នួនះ** ការប្តឹងសាលាក្រុងនេះ មិនប៉ះពាល់ដល់ការឃោសនារបស់ខ្ញុំទេ តែជាឱកាសដែលឱ្យសាលាក្រុងឡូវែលដោះស្រាយឱ្យបានឆាប់កុំឱ្យតុលាការជាអ្នកសម្រេច ពីព្រោះមិនល្អមើលសម្រាប់ក្រុងទេ។ ទីតាំងរបស់វិទ្យាល័យឡូវែល ខ្ញុំឃើញថា ទីតាំងនៅ"ដោនថោន"ប្រសើរជាង៕






## Neighborhoods of Lowell, MA

### Hotels

| # | Hotels | |
|---|---|---|
| H5 | Best Western Plus Chelmsford Inn | |
| H2 | Courtyard Marriott | |
| H3 | Hawthorne Suites | |
| H6 | Motel 6 | |
| H4 | Radisson Hotel & Suites | |
| H7 | The Stonehedge Inn & Spa | |
| H1 | UMass Lowell Inn & Conference Center | B6 |

### Public Services

| # | Public Services | |
|---|---|---|
| 1 | City Hall | A5 |
| 2 | Health Department | E2 |
| 3 | Pollard Memorial Library | A5 |
| 4 | Registry of Motor Vehicles | B5 |
| | Fire Department | |
| | Police Station | |
| | District Court | B6 |
| | Superior Court | C5 |
| | Hospital | |
| | US Post Office | A5 |

### Public Parking

| | | |
|---|---|---|
| | Entrance to Cambodia Town | C4 |
| | Glory Buddhist Temple | D4 |

### Parks & Recreation

| # | Parks & Recreation | |
|---|---|---|
| 1 | Edward A. LeLacheur Park (Lowell Spinners) | A4 |
| 2 | North Common | A4 |
| 3 | Clemente Park | C4 |
| 4 | South Common | C5 |
| 5 | Tsongas Center | A5 |
| 6 | Vandenberg Esplanade | B1 |

UMASS LOWELL
Inn & Conference Center
fifty 5 warren
RESTAURANT & LOUNGE
accommodations
flexible event space
inventive dining
978-934-6920 • www.uml.edu/icc

### Organizations

| # | Organizations | |
|---|---|---|
| 1 | Angkor Dance Troupe | B6 |
| 2 | Cambodian Mutual Assistant Association | C3 |
| 3 | Cambodia Town of Lowell, Inc. | E1 |
| 4 | Merrimack Valley Food Bank | B3 |
| 5 | Greater Lowell Chamber of Commerce | A5 |
| 6 | Greater Merrimack Valley Convention and Visitors Bureau | B5 |

### Colleges

| # | Colleges | |
|---|---|---|
| 1 | Middlesex Community College | B6 |
| 2 | UMass Lowell | A5 |

### Restaurants

| # | Restaurants | |
|---|---|---|
| 1 | Athenian Corner | B5 |
| 2 | Delish Restaurant & Bar | A5 |
| 3 | Heng Lay | D3 |
| 4 | Le Petit Café | C4 |
| 5 | New Asia | B5 |
| 6 | Peephuptmei | C3 |
| 7 | Phnom Penh | D3 |
| 8 | Red Rose | C4 |
| 9 | Simply Khmer | D4 |
| 10 | Viet-Thai Restaurant | A5 |

### Bakeries & Coffee

| # | Bakeries & Coffee | |
|---|---|---|
| 11 | Little Delights Bakery | B5 |
| 12 | Morning Star | C4 |
| 13 | Top Donut | A6 |

### Function Halls

| # | Function Halls | |
|---|---|---|
| 14 | Hong Kong | D3 |
| 15 | Pailin City | C4 |
| 16 | Sompao Meas | E4 |
| 17 | Sunny Da | E4 |



## Attractions

| # | Attraction | Grid |
|---|---|---|
| 1 | American Textile History Museum | B4 |
| 2 | Boarding House Park | A6 |
| 3 | Boott Cotton Mills Museum | A6 |
| 4 | Kerouac Park | A6 |
| 5 | Lowell Memorial Audiorium | B6 |
| 6 | Lowell National Historical Park Visitor Center | B5 |
| 7 | Merrimack Repertory Theatre | B6 |
| 8 | Mill No. 5 | B5 |
| 9 | Mogan Cultural Center | A5 |
| 10 | New England Quilt Museum | B5 |
| 11 | Whistler House Museum of Art | B5 |

## Markets & Grocery

| # | Market | Grid |
|---|---|---|
| 1 | Angkor Thom Market | E4 |
| 2 | Bangkok Market | D4 |
| 3 | Hong Kong Supermarket | D3 |
| 4 | K Market | D3 |
| 5 | Lim Nini's Seafood Market | B4 |
| 6 | Market Basket | B4 |
| 7 | Mill City Grows | C4 |
| 8 | Ocean Garden Market | A4 |
| 9 | Pailin Asian Supermarket | C4 |
| 10 | Phnom Penh Market | C4 |
| 11 | The 99 Store | D3 |
| 12 | V-Mart Int'l Market | C6 |

## Services

| # | Service | Grid |
|---|---|---|
| 1 | KhmerPost USA Newspaper | A6 |
| 2 | K-Pharmacy | D3 |
| 3 | Lico Wireless | D3 |
| 4 | Law Office of Louis Haskell | D3 |
| 5 | Law Office of Thomas Stylianos | C5 |
| 6 | Lowell Flower House | D4 |
| 7 | Magic Wireless | C4 |
| 8 | Phnom Penh Int'l Travel Services | C4 |
| 9 | Sros Salon | B4 |
| 10 | Tepsou Bridal | D4 |

## Shops & Boutiques

| # | Shop | Grid |
|---|---|---|
| 1 | Amara Boutique | C4 |
| 2 | Apsara Jewelry | C4 |
| 3 | Dollar Buy | B6 |
| 4 | Humanity Boutique | B5 |
| 5 | P&P Jewelry | C4 |
| 6 | Pailin Jewelry | C4 |
| 8 | Phnom Pech Jewelry | C4 |
| 9 | Prasat Meas Jewelry & Pawn | C4 |
| 10 | Western Avenue Studios | C4 |

## Walking | Driving Map



# ព្រះតេជគុណ សៅ យន ស្ថាបនិកឡូវែលមួយអង្គចូលទីវង្គត់ហើយ

**ខ្មែរផុសស.រ.អា.**

ម៉ោង៩,៥០នាទីព្រឹកថ្ងៃទី១០កញ្ញា២០១៧ ព្រះគ្រូចៅអធិការវត្តខ្មែរឡូវែល សៅ យន បានចូលទីវង្គត់ក្នុងព្រះជន្មាយុ៨៤វស្សាដោយរោគាពាធ ។ ព្រះអង្គគង់ជាចៅអធិការនៅវត្តខ្មែរដំបូងគេបង្អស់ឈ្មោះ"វត្តត្រៃរតនារាម"ស្ថិតនៅ"ឆែមហ្វិតខាងជើង ផ្លូវគ្វិកឡេ" ជាប៉ត នានឹងឡូវែលដែរ ដែលបានបង្កើតឡើង នាអម្លុងឆ្នាំ ១៩៨៥, មុននឹងក្លាយជាចៅអធិការវត្តមួយទៀត គឺវត្តខ្មែរដែលព្រះអង្គគង់នៅពីឆ្នាំ៥ឆ្នាំចុងក្រោយ រហូតដល់ពេលព្រះអង្គចូលទីវង្គត់ ។

លោកស្រី ឆាន់សីល័រ សាកលវិទ្យាល័យយូម៉ាស់ឡូ បច្ចុប្បន្ន ធ្លាប់និយាយប្រាប់យើងថា លោកស្រីធ្លាប់ជាអ្នកគ្រប់គ្រងរៀបចំសហគមន៍ខ្មែរ កាលពីឆ្នាំ១៩៨៣, មានការលំបាកមួយ



គឺសហគមន៍ខ្មែរធ្វើបុណ្យបូជាសពដែលជាពិធីសំខាន់បំផុតក្នុងគ្រួសារ តាមទំនៀមទំលាប់នៃព្រះពុទ្ធសាសនាតែពេលនោះ ពុំមានវត្ត នឹងគ្មានព្រះសង្ឃនៅឡូវែលនេះទេ រៀងរាល់ពេលតែងតែទៅនិមន្តព្រះសង្ឃពី"រ៉ូដអាយឡិន"មកដឹកនាំពីធីបុណ្យសព...ដែលជាហេតុឱ្យមានការក៏កើតវត្តមួយនៅពេលបន្ទាប់មក...

**ព្រះតេជគុណ យាង សុចិត្រា** ចៅអធិការវត្តសហគមន៍ព្រះសង្ឃខ្មែរនៅក្រុង "រ៉ូដអាយឡិន" មានសង្ឃដីការនៅ២ថ្ងៃបន្ទាប់ពីព្រះគ្រូ សៅ យន ចូលទីវង្គត់ទៅហើយថា: អាត្មាមានការសោកស្តាយចំពោះការលាចាកលោករបស់ព្រះអង្គ សៅ យន នេះណាស់ ពីព្រោះព្រះអង្គមានគុណលើអាត្មាជួយខ្ញុំព្រះករុណាអាត្មាភាពគ្រប់ពេលវេលា ហើយមិនឆ្មើងឆ្មៃនឹងជួយទេ។



អាត្មានឹងនៅចងចាំពីគុណសម្បត្តព្រះ អង្គ៣យ៉ាង គឺ១-ជួយដល់ព្រះសង្ឃខ្មែរដោយគ្មាននឿយហត់ ២-ជួយលើកដំកើងសង្គមព្រះពុទ្ធសាសនាខ្មែរ ៣-ជួយដល់សហគមន៍ខ្មែរជារហូតដល់ចុងបញ្ចប់ជីវិតព្រះអង្គ។ អាត្មានៅចាំបានថា ព្រះអង្គ សៅ យន បានបង្កើតវត្តព្រះពុទ្ធសាសនា មុនគេបង្អស់ជូន សហគមន៍ខ្មែរនៅឡូវែល, ជាអ្នកជួយជ្រោមជ្រែងឱ្យកើតសមាគមខ្មែរ, ជួយជ្រោមជ្រែងឱ្យកំណើតបុណ្យអុំទូក, ជួយបង្កើត "ពេទ្យមេត្តា", ព្រះអង្គមានបន្សល់នូវស្នាដៃច្រើនណាស់...។ កាសែត"ខ្មែរផុសស.រ.អា." សូមចូលរួមមរណទុក្ខចំពោះការចូលទីវង្គត់របស់ព្រះតេជគុណ សៅ យន ប្រកបដោយការសោកស្តាយជាទីបំផុត ។ សូមវិញ្ញាណក្ខន្ធព្រះអង្គបានជួបតែបរមសុខ នៅគ្រប់ទីឋានដែលព្រះអង្គសណ្ឋិតនៅកុំបីឃ្លាតឡើយ ៕



ព្រះជីវប្រវត្តិសង្ខេប

## ព្រះសង្ឃាធិបតី ធម្មថេរោ សៅ យន

ព្រះសង្ឃាធិបតី ធម្មថេរោ សៅ យន ប្រសូត្រនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៣៦ នៅភូមិអូរ ឃុំសង្វើយ (បច្ចុប្បន្ន ឃុំឫស្សីលក) ស្រុកជីក្រែង ខេត្តសៀមរាប ព្រះរាជាណាចក្រកម្ពុជា ។ ព្រះសង្ឃាធិបតី បានទទួលអនិច្ចធម្មទៅ នៅថ្ងៃអង្គារ៍ ទី១២ ខែកញ្ញា ឆ្នាំ២០១៧ នៅវេលាម៉ោង ៩.៥០ ព្រឹក នៅក្នុងបន្ទប់ចតុរង្គ ដែលមានព្រះពុទ្ធរូប ១,២៥០អង្គ នៅក្នុងបរិវេណនៃវត្តខ្មែរឡូវែល ក្រុងឡូវែល រដ្ឋម៉ាស្សាឈូសែត សហរដ្ឋអាមេរិក ។ ព្រះអង្គមានព្រះជន្ម ៨៤វស្សា ។ ព្រះបានស្ថិតនៅក្នុងភេទជាព្រះសង្ឃជាង ៧០ ឆ្នាំ ។

ព្រះសង្ឃាធិបតី ធម្មថេរោ សៅ យន បាននិមន្តមកគង់នៅសហរដ្ឋអាមេរិក តាមការធានាដោយសម្តេចព្រះមហាឃោសានន្ទ និងលោកប៉ាស្ទ័ កីធី ផន នៃសហគមន៍កាតូលិក នៅឆ្នាំ១៩៨៥ ។

**កម្រិតសិក្សា៖**

- បរិញ្ញាប័ត្រ - ពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត និងពុទ្ធិកវិទ្យាល័យព្រះសីហនុរាជ ភ្នំពេញ ប្រទេសកម្ពុជា ឆ្នាំ១៩៧២-១៩៧៤ ។
- សាលាអាណាចក្រ បញ្ចប់ការសិក្សាថ្នាក់ទី៧ កាលនៅជាគ្រហស្ថ និងបន្តការសិក្សានៅសាលាគរុកោសល្យអនុវត្តន៍ ព្រមទាំងឧត្តមសិក្សា ទីក្រុងភ្នំពេញ ពីឆ្នាំ១៩៥១ ដល់១៩៥៣

ចំណេះផ្នែកភាសា ៖ ភាសាខ្មែរ, អង់គ្លេស, បាលី, សំស្ក្រឹត, សៀម, លាវ, និងបារាំង ។

**វិស័យព្រះពុទ្ធសាសនា ៖**

- កសាងព្រះផ្នួសជាសាមណេរ កាលពីព្រះជន្ម ១៤វស្សា ក្នុងឆ្នាំ១៩៤៨ នៅវត្តខ្សាច់ ។
- កសាងព្រះផ្នួសជាព្រះភិក្ខុ កាលពីព្រះជន្ម ២០វស្សា ក្នុងឆ្នាំ១៩៥៤ រហូតដល់ថ្ងៃព្រះអង្គចូលអនិច្ចធម្ម នៅ ថ្ងៃអង្គារ៍ ទី១២ ខែកញ្ញា ឆ្នាំ ២០១៧ នៅវេលាម៉ោង ៩.៥០ ព្រឹក

**វិស័យបម្រើសាសនា សង្គមកិច្ច និងសាធារណៈ ៖**

- ស្ថាបនិកជន និងព្រះប្រធាន សហគមន៍ព្រះសង្ឃខ្មែរ សហរដ្ឋអាមេរិក ចាប់តាំងពីថ្ងៃទី២១ ខែមិនា ឆ្នាំ១៩៩៣ រហូតដល់ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៧ ។
- ស្ថាបនិកជន និងព្រះចៅអធិការ វត្តខ្មែរឡូវែល ក្រុងឡូវែល រដ្ឋម៉ាស្សាឈូសែត សហរដ្ឋអាមេរិក ចាប់តាំង ពីថ្ងៃ២២ ខែធ្នូ ឆ្នាំ២០១១ រហូតដល់ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៧ ។
- សហស្ថាបនិក និងព្រះគ្រូទីប្រឹក្សាផ្នែកសាសនានិងវប្បធម៌ខ្មែរ "ពិធីបុណ្យអុំទូកអាស៊ីអាគ្នេយ៍" ប្រចាំក្រុងឡូវែល រដ្ឋម៉ាស្សាឈូសែត សហរដ្ឋអាមេរិក កំឡុងឆ្នាំ ១៩៩៦ ដល់ ១៩៩៩ ។
- ព្រះគ្រូចៅអធិការដឹកនាំមហាបុណ្យពុទ្ធាភិសេក តម្រប់ចំនួន៤លើក
- ស្ថាបនិកជន និងព្រះគ្រូចៅអធិការ វត្តត្រៃរតនារាម ចាប់ពីឆ្នាំ១៩៨៥ ដល់ ឆ្នាំ១៩៩៣ ទីក្រុងណតឆាមស៊ិត រដ្ឋម៉ាស្សាឈូសែត សហរដ្ឋអាមេរិក ។
- សមាជិកគណៈកម្មការនៃសមាគមខ្មែរ រដ្ឋម៉ាស្សាឈូសែត ចាប់ពីឆ្នាំ១៩៨៥ ដល់ ១៩៨៦ ។
- ទីប្រឹក្សានិងត្រឹះមូលដ្ឋានស្ថាបនិកមណ្ឌលសុខភាពពេទ្យ "មេត្តា" នៅទីក្រុមឡូវែល រដ្ឋម៉ាស្សាឈូសែត សហរដ្ឋអាមេរិក ឆ្នាំ១៩៩៨ ។
- ស្ថាបនិកជន បង្កើតបញ្ជីរាយនាមនិងអាស័យដ្ឋានវត្តខ្មែរ នៅសហរដ្ឋអាមេរិក, កាណាដា, បារាំង ឆ្នាំ១៩៩៣ នៅទីក្រុង ណត ឆាមស៊ិត រដ្ឋម៉ាស្សាឈូសែត ។
- អ្នកឧបត្ថម្ភ និងធានាព្រះភិក្ខុសង្ឃខ្មែរជាច្រើនអង្គ ឲ្យមកបន្តការសិក្សានិងជួយផ្សព្វផ្សាយព្រះពុទ្ធសាសនា ដល់ពុទ្ធបរិស័ទខ្មែរនៅទីក្រុងឡូវែល និងនៅតាមតំបន់នានានៅសហរដ្ឋអាមេរិក ។
- ទីប្រឹក្សា សមាគមខ្មែរ ចាប់ពីឆ្នាំ១៩៨៦ រហូតដល់ឆ្នាំ២០០២ នៅទីក្រុងឡូវែល រដ្ឋម៉ាស្សាឈូសែត សហរដ្ឋអាមេរិក ។
- ប្រធានសហគមន៍ព្រះសង្ឃខ្មែរ ឆ្នាំ១៩៩៣ រហូតដល់ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៧ សហរដ្ឋអាមេរិក ។

**វិស័យទំនាក់ទំនងអន្តរជាតិ ៖**

- និមន្តទៅគាល់ព្រះមហាក្សត្រខ្មែរ សម្តេច នរោត្តម សីហនុវ៉ឺន នៅប្រទេសកម្ពុជា ដើម្បីថ្វាយសញ្ញាប័ត្រ អគ្គពុទ្ធសាសនូបត្ថម្ភ តាមរយៈសម្តេចព្រះមហាឃោសានន្ទ នៅខែមេសា ឆ្នាំ២០០២ ។
- និមន្តចូលរួមសន្និបាតសន្តិភាព នៅប្រទេសអ៊ីស្រាអែល ដឹកនាំដោយសម្តេចព្រះមហាឃោសានន្ទ ដែលជាសមាជិកក្រុមប្រឹក្សាសន្តិភាពពិភពលោក ។
- និមន្តចូលរួមសន្និបាតព្រះពុទ្ធសាសនា នៅប្រទេសជប៉ុន ។

សហគមន៍ព្រះសង្ឃខ្មែរ
COMMUNITY OF KHMER BUDDHIST MONKS, INC.
វត្តខ្មែរឡូវែល និង មជ្ឈមណ្ឌលវប្បធម៌ខ្មែរ
VATT KHMER LOWELL & KHMER AMERICAN AMERICAN CULTURAL CENTER
*A Temple of Hope and a Center of Renewal*
48 Townsend Avenue | Lowell, Massachusetts 01854
Phone: (978) 323-9447 | Fax: (978) 656-8031 | VATTKHMERLOWELL.ORG

វត្តខ្មែរ VATTKHMER

### ពិធីបុណ្យព្រះសពព្រះប្រធានសហគមន៍ព្រះសង្ឃខ្មែរ ព្រះសង្ឃាធិបតី ធម្មថេរោ សៅ យន



ខ្ញុំព្រះករុណាអាត្មាភាព យើងខ្ញុំជាសមាជិក សមាជិកានៃសហគមន៍ព្រះសង្ឃខ្មែរ, វត្តខ្មែរឡូវែល, មជ្ឈមណ្ឌលវប្បធម៌ខ្មែរនិងពុទ្ធបរិស័ទទាំងអស់ មានទុក្ខជាទម្ងន់ ដោយព្រះសង្ឃាធិបតី **ធម្មថេរោ សៅ យន**, ព្រះប្រធានសហគមន៍ព្រះសង្ឃខ្មែរសហរដ្ឋអាមេរិក បានទទួលព្រះអនិច្ចធម្ម នៅវេលាម៉ោង ៩.៥០ព្រឹក ថ្ងៃអង្គារ៍ ទី១២ ខែកញ្ញា ឆ្នាំ២០១៧ ដោយរោគាពាធ ក្នុងព្រះជន្ម ៨៤ ព្រះវស្សា ។

ព្រះសពនេះនឹងតម្កល់ទុកក្នុងម្ឈូសមាស សម្រាប់ធ្វើបុណ្យទក្ខិណានុប្បទានតាមប្រពៃណីព្រះពុទ្ធសាសនា រយៈពេលចំនួន៥៩ថ្ងៃ នៅវត្តខ្មែរឡូវែល *48 Townsend Ave.; Lowell, Massachusetts 01854* គឺចាប់ពីថ្ងៃសុក្រ ទី១៥ ខែកញ្ញា ឆ្នាំ២០១៧ រហូតដល់ថ្ងៃអាទិត្យ ទី១២ ខែវិច្ឆិកា ឆ្នាំ២០១៧ ។

សេចក្តីប្រគេននិងជូនដំណឹងដូចខាងលើនេះ ចាត់ទុកជាការនិមន្តនិងគោរពអញ្ជើញ ព្រះករុណាគ្រប់ព្រះអង្គ និងពុទ្ធបរិស័ទ ជិតឆ្ងាយទាំងអស់ ព្រះមេត្តានិងមេត្តាជ្រាបជាពត៌មាន ហើយសូមនិមន្តនិងអញ្ជើញ ចូលរួមក្នុងពិធីបុណ្យព្រះសពនេះ ឲ្យបានអធឹកអធម តាមកាលបរិច្ឆេទ ដូចខាងក្រោម ៖

**កម្មវិធីបុណ្យដង្ហែព្រះសពមកកាន់វត្តខ្មែរឡូវែល**

**ថ្ងៃ១០រោច ខែភទ្របទ ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១ - ត្រូវនឹងថ្ងៃសុក្រ ទី១៥ ខែកញ្ញា ឆ្នាំ២០១៧**

| | |
|---|---|
| ម៉ោង ២.៣០ រសៀល | ដង្ហែព្រះសពពីកន្លែងតម្កល់ព្រះសពបណ្តោះអាសន្ន មកកាន់វត្តខ្មែរឡូវែល |
| ម៉ោង ៣.០០ រសៀល | បង្សុកូលឧទ្ទិសបុណ្យកុសលប្រគេនព្រះវិញ្ញាណក្ខន្ធ,បាតុកថា និងធម្មទេសនា |
| ម៉ោង ៤.៣០ - ៩.០០យប់ | ព្រះភិក្ខុសង្ឃ និងពុទ្ធបរិស័ទគោរពព្រះដួងវិញ្ញាណក្ខន្ធព្រះសព |

**កម្មវិធីបុណ្យទក្ខិណានុប្បទានប្រគេនព្រះសព**

**ចាប់ពីថ្ងៃ១១រោច ភទ្របទ ដល់ថ្ងៃ៨រោច កត្តិក - ថ្ងៃសៅរ៍ ទី១៦ កញ្ញា ដល់ថ្ងៃអាទិត្យ ទី១២ វិច្ឆិកា ឆ្នាំ២០១៧**

| | |
|---|---|
| ម៉ោង ៩.០០ ព្រឹក | នមស្ការព្រះរតនត្រៃ សមាទានសីល រាប់បាត្រ ជារបង្សុកូល |
| ម៉ោង ១១.០០ ព្រឹក | វេរចង្ហាន់ប្រគេនព្រះភិក្ខុសង្ឃ និងឧទ្ទិសកុសល |
| ម៉ោង ៥.០០ - ៩.០០យប់ | នមស្ការព្រះរតនត្រៃ សមាទានសីល ចម្រើនព្រះបរិត្ត និងសម្តែងធម្មទេសនា |

**កម្មវិធីបុណ្យឆ្លងព្រះសព**

**ថ្ងៃ៨រោច ខែកត្តិក ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១ - ត្រូវនឹងថ្ងៃសៅរ៍ ទី១១ ខែវិច្ឆិកា ឆ្នាំ២០១៧**

| | |
|---|---|
| ម៉ោង ៤.០០ - ៩.០០ យប់ | នមស្ការព្រះរតនត្រៃ, សមាទានសីល, ចំរើនព្រះបរិត្ត និងធម្មទេសនាត្រៃប្រាំ |

**ថ្ងៃ៩រោច ខែកត្តិក ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១ - ត្រូវនឹងថ្ងៃអាទិត្យ ទី១២ ខែវិច្ឆិកា ឆ្នាំ២០១៧**

| | |
|---|---|
| ម៉ោង ៩.០០ ព្រឹក | នមស្ការថ្វាយបង្គំព្រះរតនត្រៃ សមាទានសីល និងនិមន្តព្រះសង្ឃគោចរបិណ្ឌបាត្រ |
| ម៉ោង ១១.០០ ព្រឹក | វេរចង្ហាន់ប្រគេនព្រះភិក្ខុសង្ឃ ដើម្បីឧទ្ទិសកុសលប្រគេនព្រះសព |
| ម៉ោង ១.០០ រសៀល | ដង្ហែព្រះសពទៅតម្កល់ទុកក្នុងកុដិព្រះពុទ្ធរូបប្រាំពាន់អង្គ ជាកិច្ចបង្ហើយបុណ្យ |

**ពត៌មានបន្ថែម** សូមទំនាក់ទំនង៖

ព្រះភិក្ខុ បញ្ញាបទីបោ **ប៉ាត សុផល** (781) 484-7302
ព្រះភិក្ខុ ធម្មប្បញ្ញោ **ខ៉ាត់ សុខុន** (978) 726-1736
អ្នកស្រី **ម៉ាយ៉ា ម៉ែន** (978) 501-0106
ព្រះភិក្ខុ វុឌ្ឍិធម្មោ **ស្រួយ នួចដែន** (978) 746-4776
លោក **សំខាន់ យឿន** (978) 853-5807
**ទូរស័ព្ទវត្តខ្មែរឡូវែល** (978) 323-9447

# ប្រវត្តិនំអន្សម និងជំនឿរបស់ប្រជាពលរដ្ឋខ្មែរ!

**(ភ្នំពេញ):** នំអន្សមជានំដែលប្រជាពលរដ្ឋខ្មែរស្ទើរគ្រប់ក្រុមគ្រួសារតែងតែរៀបចំវេចនំអន្សមជារៀងរាល់ឆ្នាំ មិនដែលខានក្នុងរដូវបុណ្យចូលឆ្នាំខ្មែរ ជាពិសេសរដូវបុណ្យភ្ជុំបិណ្ឌ ក្រៅពីពិធីបុណ្យទាំងពីរនេះ នៅក្នុងពិធីមង្គលការក៏គេតែងឃើញមានវេចនំអន្សមផងដែរ។ គេតែសម្គាល់ឃើញនៅមុនថ្ងៃភ្ជុំបិណ្ឌ ឬភ្ជុំធំ មួយឬពីរថ្ងៃ ប្រជាពលរដ្ឋខ្មែរតែងញាប់ដៃញាប់ជើងម្ទីម្ទារៀបចំវេចនំអន្សម ដើម្បីទុកចូលរួមក្នុងឱកាសភ្ជុំបិណ្ឌ។

នំដែលពលរដ្ឋខ្មែរនិយមវេចនោះរួមមានដូចជា: នំអន្សមជ្រូក អន្សមចេក នំគម នំបត់ ជាដើម។

អត្ថន័យរបស់នំអន្សម: "អន្សម" តាមវចនានុក្រមសម្តេចសង្ឃ ជួន ណាត បានពន្យល់ថា ជាឈ្មោះនំធ្វើដោយអង្ករដំណើបខ្ចប់ដោយស្លឹកស្រស់ (តាមធម្មតា ច្រើនប្រើស្លឹកចេក) មានរាងមូលស្មើចុងស្មើដើម ចម្អិនដោយស្ងោរ ឬអាំងក៏មាន។ អន្សម មានច្រើនប្រភេទគឺ អន្សមចេក អន្សមដាក់ចេកណាំវ៉ាទុំទាំងមូលជាស្នូល។ អន្សមជ្រូក អន្សមដាក់សាច់ជ្រូកជាស្នូល។ អន្សមដូង អន្សមដាក់ខ្ទិះដូង ឬសាច់ដូងទុំកោសលាយផង។ អន្សមអាំង អន្សមដែលចម្អិនដោយអាំង ។ល។

មូលហេតុនាំឱ្យមានការវេចនំអន្សម តាមជំនឿសាសនា: យោងតាម (Nom Ansom) ឯកសារមួយចំនួនបានឱ្យដឹងថា ក្នុងសម័យព្រះបាទជ័យវរ្ម័នទី៧ ប្រទេសកម្ពុជាប្រកាន់សាសនាព្រាហ្មណ៍ ហើយរបស់ប្រើប្រាស់ និងសម្ភារភាគច្រើនតែមានទំនាក់ទំនងនឹងសាសនា តួយ៉ាង នំអន្សមនេះជាដើម។

ក្នុងសាសនាព្រាហ្មណ៍នំអន្សម គឺតំណាងឱ្យលិង្គព្រះឥសូរ ចំណែកឯនំគមវិញ គឺតំណាងឱ្យយោនី នាងឧមា ដែលជាព្រះមហេសីរបស់ព្រះឥសូរ។ ម្ល៉ោះហើយទើបយើងតែងតែឃើញនំប្រភេទនេះក្នុងពិធីបុណ្យទានអមជាមួយនឹងឪនំគមឪ ដែលជានំប្រពៃណីខ្មែរផងដែរ។

ដោយសារជំនឿសាសនាព្រាហ្មណ៍ត្រូវបានដក់ជាប់ក្នុងផ្នត់គំនិតខ្មែរគ្រប់គ្នាទៅហើយនោះ (បើតាមសាសនាព្រះពុទ្ធ ពុំមានយកនំទៅបោះបាច ឬសែនដូច្នេះទេ មានតែសាសនាព្រាហ្មណ៍តែមួយប៉ុណ្ណោះ) ទើបខ្មែរយកនំអន្សមជ្រូក អន្សមចេក នំគម នំបត់ទាំងនេះទៅប្រគេនព្រះសង្ឃវិញ ដែលធ្វើឱ្យសាសនាទាំងពីរលាយឡំគ្នាដូចយើងឃើញសព្វថ្ងៃនេះ។

"នំអន្សម" មានដើមកំណើតតាំងពីបុរាណកាលមកក្នុងប្រវត្តិនំប្រពៃណីខ្មែរ និងត្រូវបានគេឃើញវត្តមាននំមួយប្រភេទនេះនៅក្នុងពិធីបុណ្យ ប្រពៃណីខ្មែរ ដូចជាបុណ្យចូលឆ្នាំ បុណ្យភ្ជុំបិណ្ឌ ក្នុងពិធីរៀបអាពាហ៍ពិពាហ៍ និងពិធីបុណ្យសាសនាមួយចំនួនទៀត។ ការដែលយកនំទាំងអស់នេះទៅវត្តនៅថ្ងៃភ្ជុំបិណ្ឌមកពីបុណ្យនេះក៏ដូចជា បុណ្យផ្សេងទៀត ជាប់ពាក់ព័ន្ធនឹងព្រហ្មញ្ញសាសនា។





**នំអន្សម:** ដំបូង យើងត្រូវហែកស្លឹកចេក ឬស្លឹកផ្អាវ ហើយហាលថ្ងៃឱ្យទន់ល្មមចំពោះស្លឹកចេក។ បន្ទាប់មកត្រូវយកវាមកជូតឱ្យស្អាត និងត្រូវត្រៀមខ្សែសម្រាប់ចង។ គេអាចយកដើមចេកមកធ្វើជាខ្សែក៏បាន ឬខ្សែចងធម្មតាក៏បាន។ បន្ទាប់មកទៀត ត្រូវលាងអង្ករដំណើបទុកឱ្យស្ងួត ហើយទឹកអង្ករដំណើបនោះត្រូវលាយអំបិលតិចៗ ដើម្បីបង្កើនឱជារស ហើយត្រូវលាងសណ្តែកលឿងទុកឱ្យស្រស់ទឹក។ បន្ទាប់ពីនោះ យើងត្រូវហាន់សាច់ជ្រូកជាចង្វាយវែងល្មម (ភាគច្រើនគេយកសាច់ជ្រូកបីជាន់ ដោយសារវាមានជាតិខ្លាញ់តិចៗ) ដោយលាយគ្រឿងដូចជា ម្រេច អំបិល ម៉ើមខ្ទឹមស ជាដើម។

ក្រោយមក យើងអាចវេចបានហើយ។ ការវេចយើងត្រូវចំណាយពេលពី១ ទៅ២ម៉ោង អាស្រ័យទៅលើចំនួនអង្ករដែលយើងវេច។ ដំបូងយើងត្រូវលាស្លឹកចេកទ្រាប់លើគ្នាឱ្យក្រាស់ល្មម ហើយត្រូវដាក់អង្កររាយលើស្លឹកចេក បន្ទាប់មករោយសណ្តែកលឿងពីលើរួចដាក់សាច់ជ្រូកពីលើ ហើយបត់ចុងនៃស្លឹកទាំងពីរចូលគ្នា។

បន្ទាប់ពីវេចហើយត្រូវឆ្លងកាត់ដំណាក់កាលមួយទៀត គឺចង។ ការចងនំមិនមែនជាការងាយនោះទេ។ យើងត្រូវចងឱ្យណែនល្អ បើមិន ដូច្នេះទេនៅពេលស្ងោរទឹកអាចចូលក្នុងនំ ដែលអាចធ្វើឱ្យអង្កររលាយចេញ។ បន្ទាប់ពីចងហើយយើងត្រូវយកទៅស្ងោរ។

ការស្ងោរត្រូវចំណាយពេលប្រមាណពី៥ ទៅ៦ម៉ោង ទម្រាំតែឆ្អិនល្អ។ យើងត្រូវនៅចាំមើលជាប់ជានិច្ច យើងត្រូវមើលភ្លើងឱ្យបានជិតដល់ ហើយត្រូវប្រែនំទៅម្ខាងទៀត ដើម្បីឱ្យនំឆ្អិនបានល្អ៕



"ទស្សនៈចំពោះហ្វេសប៊ុក"

# អ្នកជាវិរបុរសរបស់ខ្ញុំ

**ដោយ ពិន សំខុន**

មិនទាន់ទាំងចេញដំណើរផង "ហ្វេសប៊ុក" សារឹត ស្រី នាយប់ទី១៤កញ្ញា បានបញ្ជូនសារពីការរៀបចំដំណើរដែលពាក្យខ្មែរក្រហមថា "សស្រាក់សស្រាំ"របស់ក្រុមធ្វើដំណើរពីឡូវែលទៅរដ្ឋធានីវ៉ាស៊ីនតោន។ មុននេះបន្តិច សារហ្វេសប៊ុករបស់ ចិត្រា កែវ ថាទៅ "ធ្វើបាតុកម្មនេះ ជាការឥតបានការទេ!"ធ្វើឱ្យខ្ញុំឆ្លើយតបទៅសារសារ៉ីទ្ធ ស្រី វិញភ្លាមថា "អ្នកជាវិរបុរសរបស់ខ្ញុំ!"។

សម្រាប់ខ្ញុំកាយវិការចាប់អារម្មណ៍ចំពោះប្រទេសជាតិរបៀបនេះ គួរឱ្យគោរពនឹងកោតសសើរពន់ពេកបាតុកររាប់រយ ឬរាប់ពាន់អ្នកបានស្កាត់ពីទិឆ្ងាយៗដើម្បីទៅជួបប្រជុំគ្នានៅរដ្ឋធានីវ៉ាស៊ីនតោន មុខវិមានក្រសួងកិច្ចការបរទេសកាលពីថ្ងៃសុក្រទី១៥កញ្ញា២០១៧ ដើម្បីសម្តែងមតិប្រឆាំងនឹងសកម្មភាពអយុត្តិធម៌នឹងទុច្ចរិតរបស់រដ្ឋបាលប្រទេសកម្ពុជាដែលចុងក្រោយបង្អស់នេះបានចាប់យ៉ាងរំលោភប្រធានគណបក្សដ៏ធំមួយ គឺលោក កឹម សុខា យកដាក់ពន្ធនាគារ។ គួរឱ្យគោរពនឹងកោតសសើរជាពន់ពេក ចំពោះវិរភាពដែលជាកាយវិការប្រកបដោយការលះបង់ខ្ពស់ ដើម្បីគំនិតដ៏ត្រឹមត្រូវការពារការរំលោភលើលោក កឹម សុខា នឹងប្រជាពលរដ្ឋខ្មែរ។

លោកអ្នកនឹងយុវនារីយុវជន បានទិញសំបុត្រ ៦០ដុល្លាសម្រាប់ជិះរថយន្តឈ្នួលទៅមកឡូវែល-វ៉ាស៊ីនតោនឌីស៊ីក្នុងដំណើរទៅមកគ្មានកន្លែងដេកពួនផ្លាស់សំលៀកបំពាក់នឹងគ្មានកន្លែងបត់ដែបត់ជើង ខ្លះចំណាយថ្លៃធ្វើការមួយថ្ងៃខ្លះទិញសំបុត្រកុប៉ាលហោះមកធ្វើបាតុកម្ម...គឺក្នុងបំណងតែមួយទៅ"ធ្វើបាតុកម្មសម្តែងឆន្ទៈដ៏ត្រឹមត្រូវ"របស់ខ្លួនរួមគ្នាជាមួយបងប្អូនឯទៀតៗ ដើម្បីឱ្យបានសម្លេងរឹតតែពូខ្លាំងឡើង អាចជួយបងប្អូននៅឯកម្ពុជាឱ្យរឹតតែមានប្រសិទ្ធិភាព។ អ្នកនៅតិចសាសនៅមេនិសូតានៅណេតការ៉ូឡាយណានៅឡុងប៊ិច...។ល។ ក៏បានធ្វើការលះបង់នេះដូចៗគ្នានេះដែរ ក្នុងចំនួនច្រើនរយនាក់ ក្នុងបុព្វហេតុដូចគ្នា។ ចំនួននេះច្រើនណាស់បើប្រៀបធៀបទៅបាតុកម្មពីមុនៗ ដែលដំណាងឱ្យអ្នកដែលមានវិរភាពខ្ពស់បំផុត នៅឯបរទេសចូលរួមឈឺចាប់នឹងសុខទុក្ខបងប្អូនខ្មែរនៅឯកម្ពុជា។

វិរភាពនេះ ជាដំណោះស្រាយសន្តិភាពដ៏ខ្លាំងក្លាបញ្ជូនសារទៅរដ្ឋបាលអាមេរិកកាំងទៅរដ្ឋបាលសហគមន៍អឺរ៉ុប រដ្ឋបាលអូស្ត្រាលី ប្រជាពលរដ្ឋភាគតិចនៃអាស៊ីជាម្ចាស់ឆ្នោតដែរ កំពុងតែមានទុក្ខមកប្តឹងប្តល់ប្រាប់នឹងរដ្ឋបាលប្រទេសនិមួយៗឱ្យចូលរួមសកម្មភាពរំដោះកម្ពុជា ពីគ្រោះមហន្តរាយបណ្តាលមកពី "ការខ្លាចចាញ់ឆ្នោតការបាត់បង់អំណាច"របស់មេដឹកនាំខ្មែរដ៏ផ្តាច់ការឈ្មោះ ហ៊ុន សែន។ សារនេះជាជំនួយដល់ការសម្រេចចិត្តផ្នែកកិច្ចការបរទេសនៃប្រទេសមហាអំណាចឱ្យងាកទៅតាមដានស្ថានភាពនៅកម្ពុជាឱ្យបានឆាប់ បើពុំនោះទេ ជនភាគតិចភាគតិចខ្មែរនឹងមិនបោះឆ្នោតឱ្យអ្នកទៀតទេ ឆ្នោតគាំទ្រអ្នកនឹងធ្លាក់ចុះគណបក្សអ្នកនឹងអស់អំណាចគ្រប់គ្រងប្រទេសតទៅទៀត។ រីឯសារមួយទៀតបញ្ជូនទៅរដ្ឋបាលលោក ហ៊ុន សែន រដ្ឋបាលចិនរដ្ឋបាល យួន ដែលជាអណាព្យាបាលរបស់កម្ពុជាថា ដង្ហៀបទណ្ឌកម្មមហាអំណាចម្ចាស់នៃទីផ្សារពិភពលោកនឹងធ្លាក់មកលើកម្ពុជាចិននឹងវៀតណាមដែលមិនត្រូវគិតខ្លីពីប្រទេសនឹងប្រជាពលរដ្ឋរបស់ខ្លួននោះទេ។ កុំថា ការធ្វើបាតុកម្មនេះជាការឥតប្រយោជន៍ឱ្យសោះនេះជាអាវុធនៃអ្នកសន្តិភាពគេបានធ្វើមហាបាតុកម្មរបៀបនេះ ដើម្បីបញ្ឈប់សង្គ្រាមអាមេរិកាំងនៅវៀតណាមម្តងហើយ, វាធ្វើឱ្យងាប់ទាំងខ្មែរសាធារណរដ្ឋថែមទៀត... បន្ទាប់បន្តិចមកខ្មែរបានចំណាយជីវិត ២លាននាក់...។

### លីឡាយស្រេងដោះ"មីន"នយោបាយ

**Lou LaySreng Political deminer**

អតីតឧបនាយករដ្ឋមន្ត្រីនឹងជាអតីតតំណាងរាស្ត្ររដ្ឋសភាខ្មែរ អណត្តិទី១ លី ឡាយស្រេង បានថ្លែងលើហ្វេសប៊ុកយ៉ាងខ្លីមួយមានន័យថា "សម្តេច ហ៊ុន សែន ខ្លាចចាញ់ឆ្នោត បែរជាទៅចាប់ កឹម សុខា នឹងចាប់គេឯងដាក់គុក, បែរជាទៅវាយផ្ទះយកដីអ្នកស្រុកទៅវិញ? ខ្ញុំមិនយល់ទេ ខ្ញុំមិនចង់ឃើញខ្មែរឈ្លោះសម្លាប់គ្នាទៀតទេ សម្រាប់លោក ហ៊ុន សែន ចង់ឈ្នះវាស្រួលសោះ ឱ្យដីទៅគេឯងរាប់លានហិចតាបាន ហេតុអីក៏មិនឱ្យដីទៅខ្មែរ២-៣ម៉ែត្រហ្នឹង ក៏មិនបាន? ថ្មីៗនេះសម្តេចទៅសួរសុខទុក្ខរាស្ត្រនៅផ្សារថ្មី, ទៅសុខទុក្ខកម្មកររោងចក្រទៀតទៅ! គ្នាចង់បានអី? គ្នាទារប្រាក់ខែ១៦០-១៨០ដុល្លា ហេតុអី បើសម្តេចចង់ឈ្នះឆ្នោតមែន ហេតុដូចម្តេចក៏មិនឱ្យ ៣០០ដុល្លាតែម្តងទៅនៅប្រទេសជិតខាងគេធ្វើបានហេតុអីក៏យើងមានរោងចក្រដូចតែគ្នាថៅកែតែមួយដដែល គេធ្វើបានឯយើងធ្វើមិនបាន? អ្នកណាហ្នឹងឱ្យយោបល់សម្តេច ម៉េចក៏មិនប្រាប់អាហ្នឹងផងទៅ? សម្តេចធ្វើដូចសព្វថ្ងៃហ្នឹង "សន្លឹកឆ្នោតសង្គ្រោះជាតិចេះតែឡើងជិតស្មើគ្នាហើយ" ខ្ញុំប្រាប់ពីចម្ងាយទៅ ថាប្រជារាស្ត្រខ្មែរឆាប់ភ្លេចណាស់ បើសម្តេចធ្វើល្អតែ៦ខែទៅនឹងឈ្នះមកវិញហើយ, សម្តេចមិនអាចរំលាយគណបក្សសង្គ្រោះជាតិបានទេ ពីព្រោះខ្មែរយើងពឹងពាក់ទៅលើអន្តរជាតិខ្លាំងណាស់ សម្តេចបែរទៅចិនមិនបានទេ! បែរម្តងអស់២លាននាក់ ចិនមកលើកនេះ គេ"ឱ្យលុយតិចជាងគេយកទៅវិញ" ដឹងទេ?..."



អតីតឧបនាយករដ្ឋមន្ត្រី លី ឡាយស្រេង

លោក លី ឡាយស្រេង និយាយនេះ "អស់ពីពោះពីពង់ហើយ"គឺជា"គន្លឹះឈ្នះរបស់លោក ហ៊ុន សែន" ដែល ហ៊ុន សែន មិនចាំបាច់ "ចាក់ផុក"ដូចគេលេងល្បែងនោះទេ។ លោកបានបាលីដ៏សាកសិទ្ធមួយនេះ ពីលោក លី ឡាយស្រេង ឱ្យដោយមិនចេញថ្លៃមួយសេនសោះ តែលោកមិនដឹងពីបាលីនោះអាចធ្វើការជូនលោកបានប៉ុណ្ណា? ពីព្រោះលោកជាមនុស្ស"ផ្តាច់ការ"មិនចេះស្តាប់ភាសា"សេរី"នោះទេ។

**តទៅទំព័រទី១៧**



តមកទំព័រទី ១៦

# អ្នកជាវីរបុរសរបស់ខ្ញុំ...

បង្រួមសេចក្តី"បាលី"លោកស្រេង ១-ការងារ ដែលត្រូវធ្វើភ្លាមៈ ដោះលែង កឹម សុខា-ឱ្យដីផ្ទះ អ្នកស្រុកវិញ-ឱ្យប្រាក់ខែកម្មកររោងចក្រ៣០០ ដុល្លា- ២ ធ្វើល្អជាមួយខ្មែរគ្នាឯងឱ្យបាន៦ខែ- ៣ ត្រៀមចូលរួមបោះឆ្នោតដោយមិនខ្លាចចាញ់។ បាលីនេះងាយស្រួលធ្វើតាម សម្រាប់អ្នកជឿលើ "របបសេរី", ដូច្នេះសម្រាប់លោក ហ៊ុន សែន ត្រូវតែប្រឹងប្រែងពីព្រោះវាឃឹតពេលបន្តិចហើយដែរ សម្រាប់ធ្វើឱ្យ"គ្នាគាត់"ឱ្យរឹងប៉ឹងឡើងវិញ, នឹងសម្រាប់"គ្នាគេ"កុំឱ្យពង្រឹងវិញបាន។

**ហ្វេសប៊ុក"ជេម សុខ"ដុតឱ្យ ហ៊ុន សែន ផ្ទុះ** James Sok's Face book

ចូលស្តាប់ទំព័រហ្វេសប៊ុក"ជេមសុខ"១០-១៥នាទី ជាញយៗ ពេលខ្លះស្តាប់ដល់លេខក្រោយហើយ ត្រឡប់ទៅលេខមុនវិញ គួរឱ្យទាក់ទាញណាស់! ខ្ញុំបានចាប់អារម្មណ៍ដោយការប្រើពាក្យត្រជាក់ចិត្តទោះជារឿងធំក៏ដោយដោយជម្រៅនៃការប្រើចំណេះដឹងដែលធ្វើឱ្យខ្ញុំផ្តើមចូលចិត្តទំព័រហ្វេសប៊ុកខ្លះៗថែមទៀត។ ខ្ញុំជឿថា មានអ្នកអានច្រើនដែលចូលចិត្តអានទំព័រហ្វេសប៊ុក"ជេមសុខ"ជាព័ត៌មានដ៏គួរឱ្យជឿបាន ហើយយកជាជន្ទល់នៃការវិភាគព្រឹត្តិការជាតិនឹងអន្តរជាតិរបស់ខ្លួន ដោយគ្មានលាយឡំនឹងជីវិតផ្ទាល់របស់រូបលោកជេមទេ។ ទំព័រខ្លះផ្សេងទៀតនោះ ច្រើនមិនមានក្បាលកន្ទុយមានតែរូបភាពព្រឹត្តិការណ៍តែគ្មានថ្ងៃខែ ឬក៏និយាយតែពីលំអខ្លួនឯងគ្មានទាំងកំប្លែងគួរឱ្យចង់សើច ឬក៏ចង់ស្អប់ក៏មិនបានផង។


លោក ជេម សុខ

ទំព័រ"ជេមសុខ"ផ្ទុយទៅវិញ បានផ្តល់ការវិភាគទៅរកជ្រុងជ្រោយដែលគេមិនបានគិតដល់ទៅរកដំណើរនយោបាយកម្ពុជាដែលទាក់ទងលំអិតជាមួយបរទេសជាពិសេសអាមេរិកាំងទៅរកអនាគតនៃការវិវត្តន៍នយោបាយរបស់លោក ហ៊ុន សែន ដែលចេះតែតឹងទៅៗស្ទើរតែផ្ទុះទៅហើយ ។ តាមរយការវិភាគនោះលោកនាយករដ្ឋមន្ត្រីខ្មែរកំពុងតែបង្កើនធ្វើឱ្យមានការបិទរោងចក្រនៅកម្ពុជាកំពុងតែរំលាយគណបក្សប្រឆាំងដ៏មានប្រជាប្រិយភាពកំពុងតែបំប៉ោងអំណាចគ្រួសារ ហ៊ុន ឱ្យនៅពីលើកម្ពុជានឹងគណបក្សរបស់ខ្លួនមិនអាចនរណាប្រឆាំងក្រៅតែពី "ទ្រព្រះស៊ុត"បានឡើយ។ ស្រាប់តែចុងក្រោយជេមសុខបានផ្ទុះខ្លួនឯងមុន ដោយប្រើពាក្យ "ភ្លើទេឬ?""ឆ្កួតមែនទែន!"ជាច្រើនដង នៅពេលខឹងនឹង ហ៊ុន សែន មើលងាយបន្ទាបបន្ថោកអាមេរិកាំងជាហេតុធ្វើឱ្យខ្ញុំស្តាយអត្ថបទដ៏ល្អៗដែលគេធ្លាប់ជឿពីមុនមកអាចនឹងអ្នកស្តាប់មើលឃើញថា ជេម កាន់ជើងអាមេរិកាំងខ្លាំងពេកអាចនឹងមើលស្រាលពេកខាង ហ៊ុន សែន។

កាលពីព្រឹត្តិការណ៍ខែកញ្ញា២០១១នៅបូរីញូយ៉ក "ជេមសុខ"ជាមនុស្សតែម្នាក់គត់ ដែលបានផ្តល់ព័ត៌មានផ្ទាល់ភ្នែកដោយឥតតក់ស្លុតដោយឥតគិតថ្លៃជាភាសាខ្មែរផ្សាយក្នុងវិទ្យុ "អាស៊ីសេរី" ពីភេរវកម្មនៅលើ "អាគារភ្លោះកប់អាកាស"ដែលកំពុងតែរលំជូនដល់ពលរដ្ឋខ្មែរឱ្យបានដឹងដំណឹងដ៏រន្ធត់នេះ ទាន់សភាពការណ៍មុនគេបង្អស់ តាមរយៈការសម្ភាសន៍ផ្ទាល់របស់វិទ្យុអាស៊ីសេរីនាខែកញ្ញា២០១១នោះ។ តាំងពីនោះមកលោកបន្តផ្តល់ព័ត៌មានដ៏មានតម្លៃខ្ពស់គ្មានមនោសញ្ចេតនា ដូចដដែលនោះ ដោយមិនយកកម្រៃគ្មានផ្លាស់ប្តូររហូតមកដល់ថ្ងៃនេះ -គ្រាន់តែប៉ុណ្ណេះលោកអ្នកអាចយល់បានហើយថាហេតុអ្វីបានជាខ្ញុំលើកហ្វេសប៊ុក"ជេមសុខ"មកនិយាយពេលនេះ ពីព្រោះមិនដូចព័ត៌មានហ្វេសប៊ុកសង្គមឯទៀតៗ គឺវាមានតម្លៃដូចស្តាប់បណ្តាញ "ព័ត៌មានវិជ្ជាជីវៈ" ដែរ ៕

---

ព័ត៌មានខ្លីៗ

## ខ្យល់ព្យុះ

សហរដ្ឋអាមេរិកបានរងគ្រោះជាទម្ងន់ដោយខ្យល់ព្យុះបក់បោកផ្ទួនៗបន្តគ្នាៈ មានខ្យល់ព្យុះ "ហារវេយ" បន្ទាប់មកស្ទើរតែជាន់គ្នាមានខ្យល់ព្យុះមួយទៀតឈ្មោះ



"អៀម៉ា"ទើបនឹងបញ្ចប់កំហឹងកំរិត៨របស់ខ្លួនដែរនៅលើប្រជុំកោះដូមីនិកា នឹងលើដីគោករដ្ឋ ផ្លរីដា តិចសាស់ ធ្វើឱ្យខូចខាតទ្រព្យសម្បត្តនឹងជីវិតមនុស្សយ៉ាងដំណំ ។ លោកប្រធានាធិបតី ឌុណល ត្រម ទើបនឹងបញ្ចេញប្រាក់១៥ពាន់លាន សម្រាប់សងការខូចខាតទាំងនោះ ។

មិនទាន់បាន១អាទិត្យផង ខ្យល់ព្យុះមួយទៀតឈ្មោះ"ម៉ារីយា"ក៏បង្ហាញខ្លួនក្នុងកំហឹងកំរិត៣នាថ្ងៃសៅនឹងអាទិត្យនេះនៅកោះដូមីនីកាម្តងទៀត កោះព័រតូរិកូ កោះបាហាម៉ាស ដែលគេសង្ស័យថានឹងមកដល់ឆ្នេរខាងកើតយើងនេះនៅថ្ងៃចន្ទនឹងអង្គារនេះ ហើយ អាចនឹងប៉ះពាល់ដំបន់ ញូអិនគ្លិន ផងដែរ។

## លោក ហុង ណោត ជាប់ឆ្នោតជុំទី១

**សាលាក្រុងលីនៈ** យើងបានទទួលដំណឹងដ៏រីករាយមួយថា លោក ហុង ណោត ជាសមាជិកក្រុមប្រឹក្សាក្រុងលីន៣អាណត្តិមកហើយ មានដើមកំណើតខ្មែរ ទើបនឹងជាប់ឆ្នោតក្នុងដំណែងដដែលម្តងទៀតនៅជុំទីមួយ កាលពីថ្ងៃទី១២កញ្ញាមុននេះ លោកទទួលបានសន្លឹកឆ្នោតចំណាត់ថ្នាក់លេខ៣ ជាចំណាត់ថ្នាក់សង្ឃឹមខ្ពស់ក្នុងចំណោម៨រូបនោះតែក៏មិនទាន់មាន នរណាត្រូវជម្រុះនៅឡើយទេ។ បេក្ខជនដែលប្រជែងគ្នាក្នុងមាន៨រូបនោះ នឹងត្រូវជម្រុះចេញ៤រូប នៅជុំទី២ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី៧វិច្ឆិការ២០១៧។



លោក ហុង ណោត និយាយថា ការប្រគួតគ្នានៅមិនទាន់ខ្លាំងក្លានៅឡើយទេ ហើយអ្នកបោះឆ្នោតក៏មិនសូវចេញច្រើនដែរ, តែចាប់ពីពេលនេះតទៅនឹងមានការចេញឃោសនាច្រើន រវាងបេក្ខជនសុទ្ធតែមានបទពិសោធន៍។ លោក ហុង ណោត នៅរក្សាសេចក្តីសង្ឃឹមច្រើន ដោយសារលោកមានកេរឈ្មោះល្អច្រើនអាណត្តិមកហើយ ទាំងក្នុងសហគមន៍ខ្មែរ នឹងសហគមន៍លីនទាំងមូលពួកគេធ្លាប់បានគាំទ្រឱ្យលោកហុង ណោត នៅរក្សាដំណែងរបស់លោក ក្នុងសន្លឹកឆ្នោតច្រើនបំផុត។ លោកបានអំពាវនាវឱ្យពលរដ្ឋខ្មែរលីនចេញទៅបោះឆ្នោតឱ្យបានគ្រប់ៗគ្នា នៅថ្ងៃ៧វិច្ឆិកាខាងមុខ។

ហើយលោកក៏ឆ្លៀតជូនពរឱ្យបេក្ខជនខ្មែរនៅឡូវែលដែរ បានជាប់ឆ្នោតទាំងអស់គ្នា មានលោក រដ្ឋា យ៉ែម លោក វ៉ាស្នា នួន លោក ប៉ាន់ សូ នឹងលោក សុខារីឆាវ ដើម្បីឱ្យមានដំណាងខ្មែរនឹងគេ។

## អ្នកនយោបាយខ្មែរនឹងមកទស្សនាឡូវែល

**ព្រះអង្គម្ចាស់ស៊ីសុវត្ថិធម្មិកោ**ជាមន្ត្រីជាន់ខ្ពស់របស់គណបក្សសង្គ្រោះជាតិនឹងជាបេក្ខជនតំណាងរាស្ត្រនៅមណ្ឌល"ខេត្រព្រះសីហនុ" មកដល់ឡូវែល នៅថ្ងៃទី២៥ រួចបន្តរដំណើរទៅមេនីសូតា មុននឹង



ត្រឡប់មកឡូវែលវិញ នៅថ្ងៃទី៣០កញ្ញា២០១៧ ។

លោក ហុង លីម ជាតំណាងរាស្ត្រអូស្ត្រាលី ដើមកំណើតខ្មែរលោកនឹងមកធ្វើទស្សនកិច្ចនៅឡូវែល ។ នៅថ្ងៃទី៣០កញ្ញា ២០១៧ លោកនឹងផ្តល់ការជួបជុំសហគមន៍ខ្មែរ នៅភោជនីយដ្ឋាន"សំពៅមាស" វេលាម៉ោង ១២ - ២ រសៀល ។

នេះជាសេចក្តីអញ្ជើញ ដល់បងប្អូនខ្មែរទាំងអស់ សូមអញ្ជើញទៅប្រស្រ័យទាក់ទងជាមួយលោក ហុង លីម ដោយមេត្រីភាព ៕

---

**លោក យឹម សុវណ្ណ** ជាសមាជិកសភានៃគណបក្សសង្គ្រោះជាតិនឹងមកកាន់ទីក្រុងឡូវែលនឹងធ្វើសន្និសិទ



មួយនៅភោជនីយដ្ឋាន សំពៅមាស ពីម៉ោង១ដល់ ៣ៈ៣០ នាថ្ងៃទី១តុលាឆ្នាំ២០១៧ ។ សូមសាធារណជនចូលរួមស្តាប់សេចក្តីរាយកាណ៍ពីស្ថានការថ្មីៗនៅកម្ពុជា៕

LOWELL COMMUNITY HEALTH CENTER
Caring for Lowell. Caring for You.

- Metta Health Center - Primary Care
មណ្ឌលមេត្តាសុខភាព-មន្ទីរពេទ្យប្រចាំគ្រួសារ
- Behavioral Health Services
កម្មវិធីសុខភាពផ្លូវចិត្ត
- Teen Programs
កម្មវិធីសម្រាប់យុវវ័យ
- Domestic Violence Program
កម្មវិធីអប់រំផ្នែកអំពើហឹង្សាក្នុងក្រុមគ្រួសារ
- Help applying for health insurance
កម្មវិធីជំនួយដាក់ពាក្យសុំការធានារ៉ាប់រងសុខភាព
- Services in Khmer, Laotian, Burmese, & Nepalese
កម្មវិធីបំរើផ្សេងៗ ជាភាសាខ្មែរ ឡាវ ភូមា និងនេប៉ាល់



PHARMACY | ឱសថស្ថាន
Pharmacy hours:
Monday - Friday 8am - 9pm
Saturday - 8:30am - 2:30pm

135 & 161 Jackson Street, Lowell | 978.441.1700 | www.lchealth.org

## រឿងប្រលោមលោក

# រឿង ចៅពិន



**នាអំឡុងឆ្នាំ១៩៥០-៦០ តើមានអ្វីកើតឡើងនៅក្នុងជីវភាពគ្រួសារខ្មែរ!** ដោយ ខ្មែរផុសស.រ.អា

**តពីលេខមុន**

រៀនបារាំងទាំងអស់គ្នាវិញ្ញាសាខ្មែរទៀតទេ... ដូច្នេះសិស្សទាំងអស់គេនិយាយបារាំងសរសេរបារាំងបានច្បាស់លាស់តាំងពីថ្នាក់ទី៦ទៅហើយ...។ មានសិស្សច្បងដែលគេរៀនមុនៗឥឡូវក្លាយជាបញ្ញាវន្តនយោបាយគេជួយណែនាំយើងច្រើន ដូចជាលោក សឺង ង៉ុកថាន់ ជាសិស្សសាលាច្បាប់ពីមុនមានលោក ឌុក រ៉ាស៊ី លោក ស៊ុម វ៉ា អ្នកនយោបាយល្បីៗទាំងនោះ យកចិត្តទុកដាក់នឹងសិស្សប្អូនគេណាស់...

-អើ គេឃើញយើងជាសិស្សក្រីក្រ មកពីស្រុកស្រែចំការឥតប្រកែរប្រកាន់យើងនោះ វាប្រសើរណាស់ទៅហើយ...លោកគ្រូតបដោយឃើញថា អ្នកធំជាច្រើន មានចរិកជាអ្នកខ្ពស់មើលងាយអ្នកក្រធ្វើឱ្យអាចារ្យៗនឹងកូនសិស្សលោកដែលអង្គុយជុំចាំស្តាប់ការឆ្លើយឆ្លងដ៏ពិរោះនេះ ឡើងច្រហរមាត់...

-កូណា អ្នកធំដែលបានរៀនសូត្រច្រើនៗតែស្លូតបូតចេះជួយយកអាសារគេឯងណាស់លោកគ្រូ! សុផានតបវិញ...

-អាត្មាជូនពរឱ្យឯងធ្វើដំណើរឱ្យបានសុខសប្បាយ ហើយរៀនចប់ឆាប់ត្រឡប់មកជួយជាតិវិញណា... លោកគ្រូសង្ឃដីការហើយ ក៏និមន្តបន្តកាងារទៀតទៅ...រីឯសុផានក៏ទៅរកកុដិលោកគ្រូសូត្រ ដែលខ្លួនធ្លាប់នៅបំរើលោកពីក្មេងៗ ដើម្បីសម្រាកមួយរាត្រីមុននឹងបន្តដំណើរនាព្រហាមស្រាងៗតាមរថយន្តឈ្នួលបន្តពេញមួយថ្ងៃទៅភូមិកំណើតខ្លួនទៀត។

ចៅពិននៅដក់អារម្មណ៏លើព្រឹត្តិការជាមួយសុផាន យ៉ាងជ្រាលជ្រៅពីព្រោះយុវជននោះរៀនដល់ថ្នាក់មន្ត្រីធំរៀនបានខ្ពស់ជាងឪពុករបស់ខ្លួនទៅទៀត តែមកដេកនៅវត្តមិនដូចមន្ត្រីស៊ីវិល ឬទាហ៊ានរបស់រាជការដែលមានឋានន្តរសក្តិធំ មានផ្ទះក៏ធំគេមិនដេកនៅវត្តទេ ពិសេសទៅទៀតនោះ ចៅពិនមិនបាននឹកដល់ថា ក្មេងវត្តសោះ តែមានលទ្ធភាពតស៊ូរហូតដល់រៀន-ចប់ថ្នាក់ខ្ពស់បំផុតនៅកម្ពុជាទៀតផង គួរឱ្យរំភើបណាស់ដែលបានមកជួបមនុស្សកំពូលរបៀបនេះ។

ព្រឹកឡើងចៅពិនក្រោកពីដំណេកសម្លឹងទៅកុដិដែលសុផានដេកពីយប់ក្រែងបានឃើញបុរសដ៏អស្ចារ្យរបស់ខ្លួនម្តងទៀត តែឃើញតែតាៗបោសសម្រាមជុំវិញកុដិជាមួយនឹងអំបោសដងវែងឮក្រោកៗតែមិនហុយដូចពេលថ្ងៃរសៀលទេ តើពូល្ងាចមិញនោះទៅបាត់ហើយឬនៅហ្ន? លោកគ្រូសូម៉េតនៅពីក្រោយខ្នងពាក់អាវក្នុងនឹងទាញយកស្នូករបស់លោករៀបនឹងចេញទៅបង្គន់ ក៏ឆ្លៀតមកសួរចៅពិនថា:

-តើឯងកំពុងរកមើលអីហ្នឹង អាចៅពិន?

-កូណាលោកគ្រូ រកមើលពូល្ងាចមិញ តើគាត់ទៅបាត់ហើយឬនៅ? ចៅពិនតប...-តើហេតុអ្វីក៏ឯង រកគេធ្វើអ្វី ធ្លាប់ស្គាល់គេដែរឬអ្វី? លោកគ្រូសួរបន្ត...

-អត់ទេលោកគ្រូ, ចៅពិនតបម្តងទៀត, គ្រាន់តែនឹកថា ពូម្នាក់នោះគាត់នៅវត្តសោះតែរៀនសូត្របានច្រើនណាស់ គាត់គួរតែធ្វើជាអ្នកធំហើយ!

-មែនហើយ! មិនយូរមិនឆាប់ សុផានមុខជានឹងក្លាយជាមន្ត្រីធំហើយ! លោកគ្រូឆ្លើយតប, តែវត្តយើងក៏បានជួយក្មេងវត្តយើងបានច្រើននាក់ហើយណា គ្រាន់តែភាគច្រើនមិនបានរៀនច្រើនដូចចៅសូផាននេះទេ ពីព្រោះប្រញាប់ទៅជួយឪពុកម្តាយគ្រួសារគេពេកណា...

-ចុះពូសុផាននោះ ម្តេចក៏មិនទាន់ទៅជួយឪពុកម្តាយគាត់ក្រែងគ្រួសារគាត់ក៏ជាអ្នកក្រដែរទេតើ? ចៅពិនរឹតតែឆ្ងល់

-លោកគ្រូរៀងទាល់ ក៏តបថា: ប្រហែលជាគេស្រឡាញ់ចំណេះវិជ្ជាខ្លាំងណាស់ហើយមើលទៅ ហើយឪពុកម្តាយគេក៏មិនចង់ឱ្យកូនឈប់រៀន នៅពេលរៀនបានខ្ពស់ណាស់ទៅហើយក៏មិនដឹង!

-តែពូសុផាននោះ ស្លូតបូតណាស់ ហើយគាត់នៅស្រឡាញ់វត្តយើងណាស់នៅឡើយណា! ចៅពិនឧទ្ទាន...

-ឯងធ្លាប់ឃើញថា អ្នកដែលបានធ្វើធំតែងមិនចូលចិត្តវត្តយើងឬ? លោកគ្រូសួរទៅវិញ ហើយក៏បន្តរដំណើរដោយមិនរង់ចាំចំឡើយ... ចៅពិនក៏មិនបានឆ្លើយ រួចលោកគ្រូក៏បន្តថា: ទៅនាំអាចៅថាចទៅលុបមុខស្បៀកពាក់ទៅព្រឹកណាស់ហើយ...

**តទៅលេខក្រោយ**

## ការិយាល័យ មេធាវី ថូម៉ាស ស្តាលីយ៉ាណូស

**Law Office of Thomas Stylianos Jr.**
**287 Appleton St. Lowell MA 01852**

- Immigration •អន្តោប្រវេសន៍
- Auto Crash •គ្រោះថ្នាក់រថយន្ត
- Divorce •លែងលះប្តីប្រពន្ធ

សូមទាក់ទង សោភា ឬ ធំ **978-459-5000 or 800-308-3766**
**www.thomasinlowell.com**

## ហាងកែសម្ផស្ស May May BEAUTY

20 Cambridge Street
Burlington, MA 01803
**(781)-272-1389**

**ការដាក់លក់ផលិតផលសម្រាប់អបអរសាទរគំរប់ខួប ១០ ឆ្នាំ**
បញ្ចុះតម្លៃពី ១៥ % - ២០% គ្រាប់ផលិតផលគ្រឿងសំអាងទាំងអស់
**ទទួលការព្យាបាលម្តងក្នុងចំណោមសេវាព្យាបាលទាំង ១០ រឺ ទាំង ១២ របស់ហាងយើងខ្ញុំ នឹងទទួលបានការព្យាបាល ២ ដងបន្ថែមដោយមិនគិតថ្លៃ**




សេវាព្យាបាលម្តងបញ្ចុះតម្លៃ៣០% ( ព្យាបាលទៅលើការបកអាម
- តំរឹមរោម ចិញ្ចើម
- ផាត់ពណ៌លើត្របកភ្នែក
- តរោមចិញ្ចើម
- គូរចិញ្ចើម/រោមភ្នែក
- ពត់រោមភ្នែក
- បំបាត់ស្នាមអុជខ្មៅ (អាចម៍រុយ )
- បំបាត់ស្នាមជាំដោយសារកំដៅថ្ងៃ និង បំបាត់សាច់ដុះនៅលើស្បែក )

សូមទំនាក់ទំនងមកកាន់លេខ **781-272-1389**ដើម្បីការណាត់ជួប

**ការផ្តល់ជូនពិសេសនេះ ផុតកំណត់នៅថ្ងៃទី ២៨ ខែកុម្ភៈ ឆ្នាំ ២០១៨**

## សេងហាងដូណាត់នៅរដ្ឋ Kentucky

ហាងបើកលក់បាន១ឆ្នាំកន្លះ, មានចំណូលរាល់ខែ ។

ហាងធំទូលាយ, នៅចំផ្លូវធំ និងមាន Drive thru.

សម្រាប់អ្នកមិនទាន់ចេះធ្វើនំ, យើងខ្ញុំនឹងបង្រៀនមួយចេះ ។

ព័ត៌មានលំអិតសូមទូរស័ព្ទមកកាន់ **(270) 484-6397**

## MARCOTTE LAW FIRM
## ក្រុមហ៊ុនមេធាវី Marcotte

45 MERRIMACK STREET
LOWELL, MASSACHUSETTS
(978) 458-1229

- សេចក្តីអន្តរាយដល់បុគ្គល
- ច្បាប់ធានារ៉ាប់រង
- សំណងបុគ្គល
- ការរំលោភបទព្រហ្មទណ្ឌ
- ពិការភាពដោយសន្តិសុខសង្គម
- គ្រោះថ្នាក់ចរាចរណ៍
- បទព្រហ្មទណ្ឌផ្លូវភេទ និងថ្នាំញៀន
- គ្រោះថ្នាក់នៅការដ្ឋាន
- ច្បាប់គ្រួសារ និងផែនការអចលនទ្រព្យ
- បំណុលអចលទ្រព្យ
- បណ្តឹងវិវាទទូទៅ
- បើកបរនៅពេលស្រវឹង និងប្រព្រឹត្តបទល្មើសពេលធ្វើចរាចរណ៍

**មានបុគ្គលិកនិយាយភាសាខ្មែរលោកអ្នកអាចហៅទូរស័ព្ទមកក្រុមហ៊ុនយើងខ្ញុំដើម្បីពិគ្រោះ**

**(978) 458-1229**

**www.marcottelawfirm.com**

## ជំណឹងរកបុគ្គលិកចែកផ្សាយ

ខ្មែរផុសស.រ.អា.ត្រូវការរកបុគ្គលិកសម្រាប់ចែកផ្សាយកាសែតនៅក្នុងតំបន់ មានឡូវែល - លីន រីវៃ - ក្រេងស្តុន រ៉ូដអាយឡិន ។ កាសែតចែក២ដង ក្នុង១ខែ ។ បេក្ខជនត្រូវមានប័ណ្ណបើកបរ នឹងធ្លាប់ស្គាល់តំបន់ច្បាស់លាស់ ។

សូមទាក់ទងមកទីស្នាក់ការយើង នៅលេខ **978 - 677 7163**

ឬទាក់ទងមក **សួបិន 978-656 8141**

KhmerPost USA
ខ្មែរផុស ស.រ.អា

*Cambodian American Biweekly Newspaper*

Connecting 10,000 Khmer-speaking households per Month with an average of 5 members per household. Free Newspaper copies are available in these cities:

Massachusetts:
- Lowell
- Lynn/Revere

Rhode Island:
- Providence
- Cranston

CELEBRATING 10 YEARS

Contact us for the Advertising Opportunity!

**978-677-7163 | http:/khmerpost.us**







# សំបុកពងទាព្រៃស្លាប.សរកឃើញនៅខ្ពង់រាបកម្ពុជា

យោងតាមសេចក្តីប្រកាសព័ត៌មានកាលពីថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០១៧ របស់អង្គការសមាគមន៏អភិរក្សសត្វព្រៃ (WCS) ឱ្យដឹងថាសំបុកសត្វទាព្រៃស្លាបសដែលមានពងចំនួន៧គ្រាប់ត្រូវបានគេរកឃើញនៅតំបន់ខ្ពង់រាបភាគខាងជើងប្រទេសកម្ពុជា ជាលើកដំបូងក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ បន្ទាប់ពីអ្នកភូមិចំនួន៣នាក់ បានរាយការណ៏មកកាន់ក្រុមអ្នកអភិរក្សរបស់ក្រសួងបរិស្ថាន និងអង្គការសមាគមអភិរក្សសត្វព្រៃ (WCS)។ សំបុកទាព្រៃស្លាបសនេះស្ថិតនៅក្នុងប្រហោងដើមគគីរដែលមានកម្ពស់ប្រមាណ១២ម៉ែត្រពីដី និងមានទីតាំងស្ថិតនៅក្នុងដែនជម្រកសត្វព្រៃគូលែនព្រហ្មទេព ក្បែរភូមិសំបូរ ឃុំស្រយោង ស្រុកគូលែន ខេត្តព្រះវិហារ ។

ទាព្រៃស្លាបសស្ថិតនៅក្នុងបញ្ជីក្រហមរបស់អង្គការ IUCN ជាប្រភេទរងគ្រោះជិតផុតពូជនៅលើសាកលលោក ពីព្រោះចំនួនរបស់ពួកវានៅបន្តធ្លាក់ចុះយ៉ាងខ្លាំងដោយសារតែការបាត់បង់ទីជម្រក ការរំខាននៅតាមដងព្រែក និងការបរបាញ់ជាដើម ។ ទាព្រៃស្លាបសមានចំនួនចន្លោះពី២៥០-១000ក្បាលនៅលើសាកលលោក និងមានវត្តមានតិចតួចរស់នៅក្នុងប្រទេសកម្ពុជា ។

លោក អ៊ិន ឡូង អាយុ៣៦ឆ្នាំ ដែលបានរកឃើញសំបុកបាននិយាយថាឪយើងបានប្រទះឃើញទាព្រៃស្លាបសមួយក្បាលនៅលើដើមឈើពេលដើរទៅស្រែ ។ យើងបានរាយការណ៏ទៅកាន់អង្គការ WCS អំពីព័ត៌មាននេះ ពីព្រោះយើងដឹងថា វាជាប្រភេទជិតផុតពូជ ។ ក្រុមអ្នកអភិរក្សនៃអង្គការ WCS បានមកពិនិត្យសំបុកហើយ ជួលពួកយើងទាំង៣នាក់ឱ្យយាមសំបុកនេះ ដោយផ្តល់ឱ្យប្រាក់កម្រៃឱ្យពួកយើងជាការតបស្នង ។

យើងរីករាយក្នុងការងារជាអ្នកយាមសំបុក ហើយនឹងខិតខំប្រឹងប្រែងធ្វើការដើម្បីកុំឱ្យមានការរំខានពីមនុស្ស ការប្រមូលយកពងកូន និងពីពពួកសត្វស៊ីសាច់ជាអាហារមួយចំនួនដែលអាចឡើងស៊ីពងរបស់វា ។ យើងរីករាយក្នុងការបំពេញតួនាទីនេះ ហើយនឹងព្យាយាមឱ្យអស់លទ្ធភាពដើម្បីសម្រេចវាឱ្យបានឱ ។

តំបន់ខ្ពង់រាបភាគខាងជើងប្រទេសកម្ពុជាក្នុងខេត្តព្រះវិហារ ដែលរួមបញ្ចូលទាំងដែនជម្រកសត្វព្រៃគូលែនព្រហ្មទេពដែនជម្រកសត្វព្រៃព្រះរកា និងដែនជម្រកសត្វព្រៃឆែបផងដែរនោះ គាំទ្រដល់ការរស់នៅរបស់សត្វស្លាបប្រភេទរងគ្រោះជាសាកលជាច្រើនប្រភេទ ។ សត្វស្លាបទាំងអស់នោះរួមមានត្រយងយក្ស និងសត្វត្មាត៣ប្រភេទដែលសត្វស្លាបទាំងអស់នេះសុទ្ធតែជាប្រភេទរងគ្រោះជិតផុតពូជបំផុតនៅលើសាកលលោកសត្វទាព្រៃស្លាបសដែលជាប្រភេទរងគ្រោះជិតផុតពូជនៅលើសាកលលោក និងសត្វព្រៃជាច្រើនប្រភេទផ្សេងទៀត ។ អង្គការ WCS កំពុងធ្វើការងាររួមគ្នាជាមួយក្រសួងបរិស្ថានដើម្បីការពារព្រៃឈើ និងសត្វព្រៃនៅតំបន់ខ្ពង់រាបភាគខាងជើងនេះ តាមរយៈសកម្មភាពអភិរក្សជាច្រើន ។ កម្មវិធីការពារសំបុកសត្វស្លាប គឺជាគម្រោងអភិរក្សមួយបង្កើតឡើងដើម្បីដោះស្រាយបញ្ហាការប្រមូលពងកូនរបស់សត្វស្លាប ។ តាមរយៈគម្រោងនេះ ប្រជាសហគមន៏រស់នៅក្នុងដែនជម្រកសត្វព្រៃគូលែនព្រហ្មទេព និងឆែប ទទួលបានប្រាក់ឧបត្ថម្ភ ប្រសិនបើពួកគាត់ទទួលបានជោគជ័យក្នុងការងារត្រួតពិនិត្យការពារ និងយាមសំបុកសត្វស្លាបសំខាន់ៗរហូតដល់ពេលកូនវាញាស់ ។ ចាប់ពីឆ្នាំ២00២ ដល់ឆ្នាំ២០១៦ សំបុកចំនួន៣.៨១៣ និងកូនសត្វស្លាបចំនួន៦ ។៨0៦កូនទទួលបានការការពារយ៉ាងល្អនៅក្នុងបរិវេណផ្ទៃដីប្រមាណ៤.000គីឡូម៉ែត្រការ៉េ ។

ដោយយោងលើការសិក្សាស្រាវជ្រាវកន្លងមក (Clements et al.2013) WCS បានប៉ាន់ប្រមាណថា កូនសត្វស្លាបប្រភេទរងគ្រោះជាសាកលចំនួនប្រមាណ៣.៧00កូនបន្ថែមទៀតបានញាស់ដែលជាលទ្ធផលចេញពីការការពារសំបុកនេះដែលកូននីមួយៗចំណាយអស់ប្រាក់ប្រមាណ១៣៤ដុល្លារ ។

លោក រស់ វ៉ាន់ ប្រធានក្រុមស្រាវជ្រាវប្រចាំដែនជម្រកសត្វព្រៃគូលែនព្រហ្មទេពនៃក្រសួងបរិស្ថាន និងអង្គការីជ្យបាននិយាយថា "បន្ទាប់ពីទទួលបានព័ត៌មានក្រុមអ្នកអភិរក្សបានចុះទៅពិនិត្យដល់ទីតាំង ។ យើងរីករាយជាខ្លាំងពេលឃើញវត្តមានមេរបស់វានៅទីនោះ និងពងបានចំនួន៧គ្រាប់" ។

លោក រស់ វ៉ាន់ បន្តថាឪទាព្រៃស្លាបសគឺជាប្រភេទរងគ្រោះជិតផុតពូជនៅសាកលលោក ដូចនេះយើងត្រូវបានបន្ថែមការអភិរក្សដើម្បីការពារពួកវាកុំឱ្យបាត់បង់ ។ ការការពារសំបុកពងកូន និងទីជម្រកមានភាពចាំបាច់ខ្លាំងណាស់ដើម្បីធានាដល់ការរស់នៅ និងបន្តពូជរបស់ពួកវា ។ យើងបានជួលអ្នកភូមិទាំង៣នាក់នោះឱ្យយាមសំបុកនេះដើម្បីកុំឱ្យមានការរំខាន និងការប្រមូលពងកូនជាដើម" ។

កម្មវិធីការពារសំបុកសត្វស្លាបនៅតំបន់ខ្ពង់រាបភាគខាងជើងប្រទេសកម្ពុជាទទួលបានការគាំទ្រពី Akron Zoo មជ្ឈមណ្ឌលសំ វ៉ាសនាសហភាពអឺរ៉ុប and Margaret A.Cargill Philanthropies (MACP) ៕

**KhmerPost USA, LLC**
**សារពត៌មានខ្មែរផុសសហរដ្ឋអាមេរិក**
អាស័យដ្ឋាន 45 Merrimack St. Suite 218A. Lowell, MA 01852
លេខទូរស័ព្ទ Phone: 978 677-7163 | Fax: (978) 677-7092
អ៊ីម៉ែល info@khmerpost.us
អានកាសែតនៅគេហទំព័រ www.khmerpost.us

**ផ្សាយពាណិជ្ជកម្ម Advertising**
អគ្គនាយកទីផ្សារ និងគ្រប់គ្រង សុបិន្ត ពិន Soben Pin, *Managing Partner*
លេខទូរស័ព្ទ 978 - 656 - 8141 (Mobile) 978 677-7163 (Office)
អ៊ីម៉ែលsobenpin@khmerpost.us

**អ្នកនិពន្ធ Editorials**
និពន្ធនាយក ពិន សំខុន Roger Samkhon Pin, *Publisher & Editor-in-Chief*
(978) 942 - 1641 | rogerpin@khmerpost.us
ការីនិពន្ធ Staff Writers:
អ្នកនិពន្ធកិត្តិយស **Contributing Writers:**
Richard Howe Jr,
**ច្នៃសោភ័ណភាពកាសែត Design Artist**
Heng Chhunleng
**ជំនួយការរដ្ឋបាល** Office Coordnator
Sochet Chhen

The KhmerPost USA is a free biweekly Cambodian newspaper and serves the Greater Merrimack Valley, Boston, and Rhode Island. It prints mostly in Khmer and provides important news and information to the people who often are isolated from the larger community due to a language barrier. This includes not only national and international news but practical local information concerning health, education, politics, businesses and community involvement. It publishes twice a month from Lowell, Massachusetts.

Mail subscription is available within the U.S. & Canada at $60.00 year.

The KhmerPost USA has full authorization from Bernard Krisher, the publisher of the Cambodia Daily to reproduce all the articles that are produced by the Cambodia Daily free of charge effective date: 6/19/2009

Follow us: Facebook | Twitter @KhmerpostUSA

តមកទំព័រទី ១០

# ស្វែងយល់ពីប្រវត្តិបុណ្យភ្ជុំបិណ្ឌ...



(ពួកប្រេត) សាច់ញាតិទាំងប្រាំពីរសណ្ដាន ព្រមទាំងតំណញាតិច្រើនមហាកប្បដែលអត់ឃ្លានអាហារអស់រយៈពេលជាច្រើនខែមកហើយនោះ ត្រូវបានរួចផុតពីការឃុំឃាំងអនុញ្ញាតឱ្យមកស្វែងរកសាច់ញាតិនៅតាមវត្តអារាមផ្សេងៗ ដែលនាំយកចំណីអាហារផ្សេងៗ មកឧទ្ទិសកុសលឱ្យខ្លួន។ ម្យ៉ាងវិញទៀត បើតាមសម្ដីចាស់ៗបុរាណ



និយាយតៗគ្នាថា ក្នុងរយៈពេល១៥ថ្ងៃ បើពពួកប្រេតជនទាំងអស់នោះ ដើរស្វែងរកញាតិចំនួន ៧វត្ត នៅតែមិនឃើញនោះ ពពួកប្រេតទាំងអស់នោះនឹងស្រែកយំទន្ទ្រាំជើង ព្រោះតែការខកបំណង និងភាពស្រែកឃ្លានក្រហល់ក្រហាយក្នុងចិត្ត។ ជាពិសេសពពួកប្រេតជនទាំងអស់នោះ នឹងជេរដាក់បណ្ដាសាដល់សាច់ញាតិកូនចៅជាមិនខាន។

**ការប្រារព្ធពិធីបុណ្យបិណ្ឌភ្ជុំ**

ចំពោះបុណ្យបិណ្ឌភ្ជុំនេះ បុរាណាចារ្យរាជបណ្ឌិតខ្មែរយើងបានរៀបចំរយៈពេល១៥ថ្ងៃ ដោយចាប់គិតពីថ្ងៃទី១រោច ដល់ថ្ងៃទី១៥រោច ខែភទ្របទ ជាពិធីមួយសម្រាប់ឧទ្ទិសកុសល ទៅដល់ប្រេតជនញាតិដែលបានស្លាប់ទៅ។ នៅក្នុងរយៈពេល ១៤ថ្ងៃ នៃការកាន់បិណ្ឌ ឬដាក់បិណ្ឌនេះ ពុទ្ធបរិស័ទចំណុះជើងវត្តទាំងអស់ជាពិសេសក្រុមនីមួយៗដែលបានរៀបចំជាក្រុមដោយលោកតាអាចារ្យចាត់ចែងនោះ ត្រូវបែងចែកចេញ ៣ឬ៤ក្រុមតូចៗ ដើម្បីរៀបចំធ្វើយាគូ (បបរ) ឬធ្វើភត្តាហារជា៣ទៅ៤ឆ្នាំង ស្មើនឹង៣ទៅ៤មុខម្ហូប។ ពេលទូងស្គរចំណាំវស្សាអ្នកនៅក្នុងក្រុមវេននីមួយៗត្រូវចាប់ផ្ដើមធ្វើចង្ហាន់ ហើយយាយតាចាស់ៗក្នុងក្រុមវេនត្រូវជ្រើសរើសយកផ្ទះណាមួយ ដើម្បីប្រមូលនំរៀបចំបាយបិណ្ឌបាយបត្តបូរ។ រៀបចំរួចហើយត្រូវនាំគ្នាទៅវត្តស្ដាប់លោកសង្ឃសូត្រថ្វាយ បង្កំធមិ សុខោ និងធមិបរាភវសូត្រ។

ចំណែកឯកូនចៅដែលនៅផ្ទះត្រូវនាំគ្នាខិតខំដុតដៃដុតជើងបបរឬស្លតាមមុខម្ហូបនីមួយៗ ដោយឡែកពីគ្នា។ លុះដល់ពេលព្រឹកព្រាងអរុណោទ័យ (ពេលព្រះអាទិត្យរះឡើង) ត្រូវនាំគ្នារៀបចំខ្លួនកណ្ដៀត យួរ កាន់ ទូល រែកចង្ហាន់ទៅវត្ត។ នៅក្នុងវត្តលោកតាអាចារ្យត្រូវរៀបចំពិធីរាប់បាត្រនៅលើឧបដ្ឋានសាលា។ បន្ទាប់មកលោកអាចារ្យជាប្រធានត្រូវនាំពុទ្ធបរិស័ទវេរ (ប្រគល់) ចង្ហាន់ប្រគេនព្រះសង្ឃវេរបាយបត្តបូរ ។ល។ លុះដល់ពេលព្រះសង្ឃធ្វើបត្តានុមោទនគាថាចប់ មេវេនក្រុមនីមួយៗត្រូវរៀបចំម្ហូបអាហារចំណីចូលគំនាប់ជូនលោកតាអាចារ្យវត្ត ព្រមទាំងចាត់ចែងភោជនាហារទទួលភ្ញៀវដែលអញ្ជើញទៅបុណ្យនៅក្នុងថ្ងៃវេនរបស់ខ្លួននោះផងដែរ ៕


## បង់ថ្លៃបូកផ្សំ $0

ណាត់ជួបវេជ្ជបណ្ឌិត $0 | ការមើលថែធ្មេញ $0 | សេវាចក្ខុវិញ្ញាណ $0

Senior Whole Health (HMO SNP) គឺជាផែនការសុខភាព Medicare Advantage មួយសម្រាប់ជនជរាអាយុ 65 ឆ្នាំឡើងទៅ ដែលមាន Medicare និង MassHealth Standard។ សមាជិកទទួលបានអត្ថប្រយោជន៍ Medicare និង MassHealth រួមបញ្ចូលទាំងការធានាលើថ្នាំតាមវេជ្ជបញ្ជា Part D បូកផ្សំនឹងអត្ថប្រយោជន៍ច្រើនទៀតដូចជា៖

- ប័ណ្ណ OTC សម្រាប់ទិញថ្នាំ និងផលិតផលិតផលទាក់ទងនឹងសុខភាពជាក់លាក់ដែលមិនចាំបាច់វេជ្ជបញ្ជា *(រហូតដល់ $300 ក្នុងមួយឆ្នាំ ឬ $75 ក្នុងមួយត្រីមាស)*
- អ្នកផ្ដល់ជំនួយតាមផ្ទះជួយអ្នកក្នុងរឿងចំណីអាហារ និងការចល័ត
- ការធ្វើដំណើរទៅមកពីកន្លែងណាត់ជួបពិនិត្យសុខភាព
- សមាជិកម្នាក់ៗទទួលបានអ្នកគ្រប់គ្រងសេវាថែទាំគិលានុបដ្ឋាកដែលសម្របសម្រួលការមើលថែទាំរបស់អ្នកដើម្បីឆ្លើយតបនឹងតម្រូវការជាបុគ្គលរបស់អ្នក។

ទាំងអស់ក្នុងផែនការងាយស្រួលតែមួយពី **Senior Whole Health**។




ប្រសិនបើអ្នកមាន MassHealth Standard តែពុំមានការធានា Medicare Part A និង/ឬ Part B ទេ អ្នកអាចនឹងមានសិទ្ធិចុះឈ្មោះក្នុងកម្មវិធី MassHealth Senior Care Options (SCO)។

SWH
SENIOR WHOLE HEALTH®
Simple. Secure. Independent.

សម្រាប់ព័ត៌មានបន្ថែម ហៅទូរស័ព្ទ៖
**1-888-566-3526**
(លេខឥតគិតថ្លៃ) **TTY/TDD:711**
**www.seniorwholehealth.com/SNP**
យើងបើកពីម៉ោង 8 ព្រឹកដល់ 8 យប់
7 ថ្ងៃក្នុងមួយសប្ដាហ៍។

*Senior Whole Health គោរពតាមច្បាប់ស្ដីពីសិទ្ធិពលរដ្ឋសហព័ន្ធ ដែលគ្រប់ដណ្ដប់ និងមិនរើសអើងពូជសាសន៍ ពណ៌សម្បុរ ដើមកំណើត អាយុ ពិការភាព ឬភេទឡើយ។*
*ATENCIÓN: si habla español, tiene a su disposición servicios gratuitos de asistencia lingüística. Llame al 1-888-794-7268 (TTY/TDD: 711).*
*ATENÇÃO: Se fala português, encontram-se disponíveis serviços linguísticos, grátis. Ligue para 1-888-794-7268 (TTY/TDD: 711).*

សុខភាពពេញលេញសម្រាប់មនុស្សចាស់ជរា (HMO SNP) និងសុខភាពពេញលេញសម្រាប់មនុស្សចាស់ជរា NHC (HMO SNP) គឺជាផែនការថែទាំសម្របសម្រួលជាមួយនឹងកិច្ចសន្យាអត្ថប្រយោជន៍ Medicare និងកិច្ចសន្យាជាមួយសហធនម៉ាសាជូសេត/កម្មវិធីសុខភាពសាធារណៈ EOHHS។ ការចុះឈ្មោះធ្វើឡើងតាមការស្ម័គ្រចិត្ត និងអាស្រ័យលើការបន្តកិច្ចសន្យាពល់ឆ្នាំ។ ព័ត៌មាននេះពុំមែនជាការពិពណ៌នាពេញលេញនៃអត្ថប្រយោជន៍ឡើយ។ ទាក់ទងផែនការនេះសម្រាប់ព័ត៌មានបន្ថែម។ អាចនឹងមានការដាក់កម្រិត ការបង់ថ្លៃបូកផ្សំ និងការកំហិត។ អត្ថប្រយោជន៍អាចផ្លាស់ប្ដូរនៅថ្ងៃទី 1 ខែមករានៃឆ្នាំនីមួយៗ។ សហធិណាយអាចប្រែប្រួលអាស្រ័យលើកម្រិតនៃជំនួយបន្ថែមដែលលោកអ្នកទទួលបាន។ សូមទំនាក់ទំនងទៅផែនការសម្រាប់ព័ត៌មានលម្អិតបន្ថែម។ ផែនការនេះអាចប្រើបានសម្រាប់អ្នកអាយុ 65 ឆ្នាំឡើងទៅ ដែលទទួលជំនួយវេជ្ជសាស្ត្រពីរដ្ឋ និង Medicare។ H2224_2016_138kh Accepted 11/25/2016

# វគ្គបណ្តុះបណ្តាលផ្នែកផលិតកម្មជាន់ខ្ពស់



## ទទួលបានវិញ្ញាបនបត្រ ខាងផ្នែក:

### មូលដ្ឋានគ្រឹះគ្រឿងម៉ាស៊ីន

*លិខិតបញ្ជាក់សិក្សាផ្នែកមូលដ្ឋានគ្រឹះគ្រឿងម៉ាស៊ីន – វិញ្ញាបនបត្រ* ***NIMS***

- កំរិត ១៖ ជំនាញមូលដ្ឋាន នៅសាលាមីដូលសិច ខាមញូនីធី ខលលិច ចាប់ពីថ្ងៃទី ៣០ ខែតុលា ដល់ខែ ធ្នូ ឆ្នាំ ២០១៧ (១០៤ ម៉ោង)
  - ថ្ងៃច័ន្ទ ដល់ថ្ងៃព្រហស្បតិ៍ – ៣:០០ រសៀល-៨:០០ល្ងាច
- កំរិត ២៖ មូលដ្ឋានគ្រឹះគ្រឿងម៉ាស៊ីន នៅសាលាវិទ្យាល័យ គ្រេតធ័រ ឡូវែល ទេចនិច ខល ហាយស្គូល ចាប់ពីខែ ធ្នូ ដល់ខែ មិនា ឆ្នាំ ២០១៨ (២៧០ ម៉ោង)
  - ថ្ងៃច័ន្ទ ដល់ថ្ងៃព្រហស្បតិ៍ – ៣:០០ រសៀល-៨:០០ល្ងាច

**រឺ**

### មូលដ្ឋានគ្រឹះគ្រឿងអេលិចត្រូនិច

*លិខិតបញ្ជាក់ផ្នែកមូលដ្ឋានគ្រឹះគ្រឿងអេលិចត្រូនិច* ***– អេលិចត្រូនិច AC & DC***

*វិញ្ញាបនបត្រ* ***J-STD & IPC***

- កំរិត ១៖ ជំនាញមូលដ្ឋាន នៅសាលាមីដូលសិច ខាមញូនីធី ខលលិច ចាប់ពីថ្ងៃទី ៣០ ខែតុលា ដល់ខែ ធ្នូ ឆ្នាំ ២០១៧ (១០៤ ម៉ោង)
  - ថ្ងៃច័ន្ទ ដល់ថ្ងៃព្រហស្បតិ៍ – ៣:០០ រសៀល-៨:០០ល្ងាច
- កំរិត ២៖ មូលដ្ឋានគ្រឹះគ្រឿងម៉ាស៊ីន នៅសាលាវិទ្យាល័យ គ្រេតធ័រ ឡូវែល ទេចនិច ខល ហាយស្គូល ចាប់ពីខែ ធ្នូ ដល់ខែ មិនា ឆ្នាំ ២០១៨ (២៧០ ម៉ោង)
  - ថ្ងៃច័ន្ទ ដល់ថ្ងៃព្រហស្បតិ៍ – ៣:០០ រសៀល-៨:០០ល្ងាច

**លក្ខខណ្ឌនៃការចុះឈ្មោះ៖** អាយុចាប់ពី ១៨ ដល់ ២៩ ឆ្នាំ, សញ្ញាបត្របាក់ឌុប, មាន *GED* រឺ *HiSET*, ពលរដ្ឋស្របច្បាប់ស្នាក់នៅអចិន្ត្រៃយ៍ និងមានសិទ្ធធ្វើការនៅអាមេរិក, ចូលបំពេញ កាតព្វកិច្ចយោធា, ត្រូវតែធ្វើតេសការអាន និងធ្វើគណិត្យវិទ្យាថ្នាក់ទី ៨, ត្រូវមានជំនាញភាសាអង់គ្លេស និងមានបទពិសោធន៍ការងារទាក់ទងនឹងការងារខាងលើ។

ការទទួលពាក្យចុះឈ្មោះមានកំណត់ រួសរាន់ឡើង ដើម្បីទទួលបានកន្លែងរបស់លោកអ្នក។ សូមទំនាក់ទំនង ▶▶▶ ▶▶▶

អាជីពធ្វើការងារខាងផ្នែកផលិត ទទួលបាន
**ប្រាក់ឈ្នួលល្អ និងអត្ថប្រយោជន៍ច្រើន**

ចាប់ផ្តើមអាជីពដែលប្រកបដោយនិរន្តរភាព ខាងផ្នែកឧស្សាហកម្មដែលមានតំរូវការខ្ពស់ មានទីតាំងងាយស្រួល ស្ថិតនៅភាគឦសាននៃរដ្ឋម៉ាសាឈូសេត ខាងផ្នែកដូចជា:

- ធ្វើយន្តហោះ
- គ្រឿងសពាវុធ
- ឧបករណ៍ពេទ្យ
- កុំព្យូរទ័រ និងអេលិចត្រូនិច
- ឱសថ និង បរិក្ខាពេទ្យ

វគ្គបណ្តុះបណ្តាលនេះ គឺមានការជួយឧបត្ថមមូលនិធិពី H-1B Tech Hire Grant តាមរយៈ ក្រសួងការងារអាមេរិក ដើម្បីផ្តល់ឲ្យចំពោះពលករដែលមានឧបសគ្គការងារ ជាពិសេសអ្នកដែលពុំមានការងារ និងពុំមានការងារធ្វើគ្រប់គ្រាន់។

Massachusetts One-Stop Career Centers
Career Center of Lowell

107 Merrimack Street Lowell, MA 01852
www.careercenteroflowell.org

**Nancy Gagnon**
**978-805-4734**
**Nancy.Gagnon@cclowell.org**

# រដ្ឋសភាអាមេរិក បានបើកផ្លូវចំពោះរថយន្តបើកបរដោយខ្លួនឯង

**ប្រែសម្រួលដោយ ខ្មែរផុស ស.រ.អ**

លោកអ្នកប្រាកដជាធ្លាប់បានដឹងអំពីបច្ចេកវិទ្យាដ៏អស្ចារ្យគឺ រថយន្តបើកដោយខ្លួនឯងដោយពុំមានអ្នកបើកបរ ។ ចំពោះបច្ចេកវិទ្យារថយន្តប្រភេទនេះ លោកអ្នកអាចធ្វើអ្វីបានតាមចិត្តពេលកំពុងនៅលើរថយន្តគឺវាទៅមុខដោយខ្លួនឯងតាមរយៈការប្រើប្រាស់បច្ចេកវិទ្យាស្វ័យប្រវត្តិ ។

នៅសហរដ្ឋអាមេរិក កាលពីថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៧ រដ្ឋសភាបានអនុម័តជាឯកច្ឆ័ន្ទនូវសេចក្តីស្នើច្បាប់មួយដើម្បីបង្កើនល្បឿនក្នុងការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍រថយន្តបើកដោយខ្លួនឯងដោយគ្មានមនុស្សគ្រប់គ្រងដោយដាក់សំណើរនេះទៅក្នុងច្បាប់សហព័ន្ធ និងដើម្បីរារាំងរដ្ឋាភិបាលពីការទុបស្កាត់ការហាមឃាត់ការប្រើប្រាស់រថយន្តស្វ័យប្រវត្តិប្រភេទនេះ នេះបើតាមសេចក្តីរាយការរបស់រ៉យទ័រកាលពីថ្ងៃពុធ ខែកញ្ញា ។

សំណើរនេះនឹងអនុញ្ញាតឱ្យក្រុមហ៊ុនផលិតរថយន្តទទួលបានការលើកលែងក្នុងការបញ្ចេញរថយន្តរហូតដល់ ២៥,000 គ្រឿងនៅក្នុងឆ្នាំដំបូងដោយមិនចាំបាច់ស្របតាមស្តង់ដារសុវត្ថិភាពរថយន្តដែលមានរួមមកហើយនោះទេ។ វិធានការនេះ នឹងធ្វើឱ្យមានកំណើនថយន្តបើកដោយខ្លួនឯងចំនួន ១00,000 គ្រឿងក្នុងមួយឆ្នាំៗសម្រាប់រយៈពេល៣ឆ្នាំ។

ក្រុមហ៊ុនផលិតរថយន្ត, ក្រុមពានិជ្ជករ, និងក្រុមធ្វើការងារជាមួយអ្នកពិការភ្នែកអបអរសាទរចំពោះវិធានការនេះ។ ប៉ុន្តែក្រុមអ្នកប្រើប្រាស់មួយក្រុម បានលើកឡើងថា រដ្ឋសភា មិនបានធ្វើឱ្យបានគ្រប់គ្រាន់ក្នុងការធានាថា រថយន្តបើកដោយខ្លួនឯង ប្រាកដជានឹងមានសុវត្ថិភាពពេលប្រើប្រាស់នៅលើដងផ្លូវ។




យោងតាមសំណើរច្បាប់ដែលបានអនុម័តនេះ ក្រុមហ៊ុនផលិតរថយន្តដែលកំពុងស្វែងរកការលើកលែងត្រូវតែបង្ហាញថា រថយន្តបើកដោយខ្លួនឯងដែលខ្លួនផលិតនោះ គឺយ៉ាងហោចណាស់មានសុវត្ថិភាពដូចរថយន្តធម្មតាដែលកំពុងចរាចរណ៍។ រដ្ឋាភិបាលនៅតែអាចកំណត់នូវច្បាប់លើការចុះបញ្ជី, ការផ្តល់អាជ្ញាប័ណ្ណ, ការទទួលខុសត្រូវ, ការធានារ៉ាប់រង និងការត្រួតពិនិត្យសុវត្ថិភាព ប៉ុន្តែមិនមែនទៅលើស្តង់ដារនៃដំណើរការរបស់រថយន្តនោះទេ។

សំណើរដែលបានអនុម័តដោយរដ្ឋសភា ឥឡូវនេះបានទៅដល់ព្រឹតសភា ហើយសមាជិកព្រឹទ្ធសភាទាំងពីរគណបក្សកំពុងតែធ្វើការលើច្បាប់ស្រដៀងគ្នានេះ។ ក្រុមហ៊ុនផលិតរថយន្ត និងបច្ចេកវិទ្យា ដូចជា ក្រុមហ៊ុន General Motors Co, Waymo និងក្រុមហ៊ុនដ៏ទៃផ្សេងទៀត សង្ឃឹមថានឹងចាប់ផ្តើមបញ្ចេញរថយន្តប្រភេទនេះនៅក្នុងរង្វង់ឆ្នាំ ២០២០។

ច្បាប់សហព័ន្ធនាពេលបច្ចុប្បន្នបានរារាំងមិនឱ្យមានការចរាចរណ៍ប្រភេទរថយន្តបើកដោយខ្លួនឯងនៅលើដងផ្លូវក្នុងសហរដ្ឋអាមេរិកនោះទេ។ រដ្ឋាភិបាលបានចេញច្បាប់ខុសគ្នាៗជាច្រើនដោយមិនមានការចង្អុលបង្ហាញច្បាស់លាស់ពីរដ្ឋបាលសហព័ន្ធ ដែលធ្វើឱ្យក្រុមហ៊ុនផលិតរថយន្តមានការថ្អូញថ្អែរពីការតឹងរឹងនៃច្បាប់ដែលមានពេលបច្ចុប្បន្ននេះ។

អ្នកជំនាញបានលើកឡើងពីអត្រាខ្ពស់នៃឧបទ្ទវហេតុគ្រោះថ្នាក់ចរាចរណ៍ ដែលបណ្តាលមកពីកំហុសរបស់មនុស្ស ដែលជាកំហុសឆ្គងសំខាន់បំផុត ហើយឈាន់ទៅរកការអភិវឌ្ឍន៍យានយន្តបំពាក់បច្ចេកវិទ្យានេះ។ យោងតាមស្ថិតិបានបង្ហាញថាប្រហែល៩៥ ភាគរយនៃគ្រោះថ្នាក់ចរាចរណ៍ទាំងអស់ គឺបង្កឡើងដោយកំហុសរបស់មនុស្ស។ ដោយសារតែប្រព័ន្ធកុំព្យូទ័រអាចមានលទ្ធភាពប្រតិកម្មរហ័ស និងអាចស្របគ្រាប់ស្ថានការណ៍ជាច្រើន ហើយធ្វើការសម្រេចចិត្តដោយមិនប្រើអារម្មណ៍ការប្រើប្រាស់រថយន្តបើកបរដោយខ្លួនឯងអាចជួយបញ្ចៀសគ្រោះថ្នាក់និងជួយសង្គ្រោះជីវិតផងដែរ៕


*For your special day...*

សម្រាប់ថ្ងៃដ៏ពិសេសរបស់អ្នក



**The UMass Lowell Inn & Conference Center** provides timeless, modern elegance with a relaxing atmosphere.

You and up to 450 guests will be catered to by our attentive staff, while you celebrate in style and comfort.

We offer overnight lodging, scenic outdoor photo opportunities, and a variety of ceremony spaces, including smaller rooms for showers, rehearsal dinners, and engagement parties.

All of our menus can be personalized to suit your individual needs.

UMASS LOWELL Inn & Conference Center

សណ្ឋាគារ យូម៉ាសឡូវែលនឹងមណ្ឌលប្រជុំ

ផ្តល់ជូនយ៉ាងទាន់ចិត្ត ជឿនលឿន សង្ហា ជាមួយនឹងបរិយាកាសយ៉ាងរំភើយ

លោកអ្នកនឹងភ្ញៀវរហូតដល់៤៥០នាក់អាចនឹងជប់លៀង ដោយមានការយកចិត្តទុកដាក់ពីបុគ្គលិកយើង នៅពេលដែលលោកអ្នកកំពុងរៀបពិធី ប្រកបដោយសម្បូរបែបនឹងយ៉ាងកក់ក្តៅ ។

យើងផ្តល់ជូនការស្នាក់អាស្រ័យឆ្លងរាត្រី, ទីធ្លាខាងក្រៅគួរឲ្យរំភើបសម្រាប់ មានឱកាសថតរូបនឹងបន្ទប់សម្រាប់ពិធីការគ្រប់ធុន,

រាប់ទាំង បន្ទប់តូច សម្រាប់បង្កក់កូន, ត្រៀមសម្រាប់ជប់លាងអាហារពេលល្ងាចនឹងពិធី ភ្ជាប់ពាក្យ...។

គ្រប់បញ្ជីមុខម្ហូបអាចនឹងរៀបចំជូនស្របតាមតម្រូវការរបស់បុគ្គលម្នាក់ៗបាន ។

**UMass Lowell Inn & Conference Center**

50 Warren St., Lowell MA 01852 978-934-6920 877-886-5422 **www.uml.edu/icc**

# REACH THOUSANDS OF PEOPLE IN THE CAMBODIAN COMMUNITY

## WITH COST EFFECTIVE NEWSPAPER ADVERTISING




### DISTRIBUTION

*70+ Locations in Lowell, MA*
*7,000 copies per month*

*25 Locations in Lynn & Revere, MA*
*1,000 copies per month*

*25 Locations in Providence & Cranston, RI*
*2,000 copies per month*

### PUBLISHING

*Two Issues Every Month*

### READERSHIP

*50,000 Monthly*
*600,000 Annually*

***Khmer Post USA Distribution Locations Include:***

- *Households*
- *Markets*
- *Retail Businesses*
- *Restaurants*
- *Office Buildings*
- *Government Offices*
- *Chamber of Commerce*
- *Buddhist Temples*
- *Laundromats*
- *And Much More*

| 2017 PRINTING DATES | 2018 PRINTING DATES |
|---|---|
| July 10 & 24 | January 5 & 19 |
| August 7 & 21 | February 5 & 19 |
| September 11 & 25 | March 5 & 19 |
| October 9 & 23 | April 6 & 20 |
| November 6 & 20 | May 7 & 21 |
| December 4 & 18 | June 8 & 2 |

***Advertising deadlines are 5 business days prior to printing date.***

### ADVERTISING RATES AND SIZES

*All ads are printed in Full Color*

| Ad Size (WxH) | 1 Issue | 3 Months (6 Issues) 5% Savings | 6 Months (12 Issues) 7.5% Savings | 12 Months (24 Issues) 10% Savings |
|---|---|---|---|---|
| **Full** (10" x 13") | $460 | $2,622 | $5,106 | $9,936 |
| **1/2** (10" x 6.5") | 310 | 1,674 | 3,441 | 6,696 |
| **1/4** (5" x 6.5") | 165 | 940 | 1831 | 3,564 |
| **1/8** (5" x 3.25") | 90 | 513 | 999 | 1,944 |

### CONTACT INFO

**45 Merrimack Street • Suite 218A • Lowell, MA 01852**
**Tel: 978.677.7163 • Fax: 978.677.7092 • Email: sobenpin@khmerpost.us**
**www.khmerpost.us**

*Khmer Post USA is a proud member of the Greater Lowell Chamber and Greater Merrimack Valley Convention and Visitors Bureau*